00293469

D138/1/5

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | ៖ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ១៨) |
| **កាលបរិច្ឆេទឯកសារ** | ៖ | ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ |
| **ភាគីបញ្ជូន** | ៖ | ការិយាល័យសហព្រះរាជអាជ្ញា |
| **ភាសាដើម** | ៖ | ភាសាអង់គ្លេស |
| **ប្រភេទឯកសារ** | ៖ | **សាធារណៈ** |

---

**សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ដែលជំទាស់ទៅនឹងដីកាសម្រេចអំពីភាពសម្ងាត់របស់សហចៅក្រមស៊ើបអង្កេត**

---

**បញ្ជូនដោយ៖**
**ការិយាល័យសហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក តាន់ សេណារ៉ុង
លោក Anees AHMED

**បញ្ជូនទៅ៖**
**អង្គបុរេជំនុំជម្រះ៖**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING QC
ចៅក្រម ន៍យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ជនត្រូវចោទ/ដើមបណ្តឹងឧទ្ធរណ៍ អៀង សារី៖**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 27 / 03 / 2009
ម៉ោង (Time/Heure): 13 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30 / 03 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fuy

D138/1/5

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៨)*

## ១. សេចក្ដីផ្ដើម

១. សហព្រះរាជអាជ្ញា ដាក់សេចក្ដីសង្កេតនេះ (“សេចក្ដីសង្កេត”) ដើម្បីជាជំនួយដល់អង្គបុរេជំនុំជម្រះក្នុងការកំណត់លើបណ្ដឹងឧទ្ធរណ៍របស់អៀង សារី (“បណ្ដឹងឧទ្ធរណ៍”)[1] ដែលស្វះស្វែងរកនូវការកែប្រែលើដីកាសម្រេច អំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ របស់សហចៅក្រមស៊ើបអង្កេត (“ដីកាសម្រេចលើភាពសម្ងាត់”)[2] ។ ដីកាសម្រេចលើភាពសម្ងាត់បានរកឃើញថា តាមរយៈការដាក់ផ្សាយឯកសារមួយចំនួននៅលើវ៉ិបសាយដែលមានការថែទាំជាឯកជនរបស់ពួកគេ (“វ៉ិបសាររបស់មេធាវីការពារក្ដី”) មេធាវីការពារក្ដីជាតិ និងអន្តរជាតិរបស់ដើមបណ្ដឹងឧទ្ធរណ៍ (ជារួមហៅថា “មេធាវីការពារក្ដី”) (១) មិនបានគោរពទៅលើ “សេចក្ដីសម្រេច” របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ ដែល “ព្រមាន” ពួកគេមិនឲ្យធ្វើដូច្នេះទេ ។ (២) បានលាតត្រដាងព័ត៌មានសម្ងាត់ដែលជាប់ទាក់ទងនឹងកិច្ចដំណើរការនីតិវិធីនៅមុនពេលជំនុំជម្រះ និង (៣) ខាកខានមិនបានអនុវត្តតាមបទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈអ្នកច្បាប់ ។ ដោយការរកឃើញអំពីបញ្ហាទាំងនេះប្រឆាំងនឹងមេធាវីការពារក្ដី សហចៅក្រមស៊ើបអង្កេតបានបញ្ជូនដីកាសម្រេចអំពីភាពសម្ងាត់ ទៅគណៈមេធាវីរៀងៗខ្លួនរបស់ពួកគេ “ដើម្បីមានវិធានការសមស្រប”[3] ។

២. បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើភាពសម្ងាត់នេះ ដោយតវ៉ា ក្នុងចំណោមបញ្ហាផ្សេងទៀតថា (១) ឯកសារទាំងអស់ ដែលបានដាក់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត មិនមែនសុទ្ធតែទទួលបាននូវកិច្ចការពារដោយភាពសម្ងាត់ឡើយ ។ (២) ឯកសារ “សម្ងាត់” ដែលបានដាក់នៅលើវ៉ិបសាយរបស់មេធាវីការពារក្ដី សុទ្ធតែជាឯកសារ “សម្ងាត់ដើម្បីការពារដល់សិទ្ធិរបស់[ដើមបណ្ដឹងឧទ្ធរណ៍] ដែលគាត់អាចលះបង់ចោល ។ (៣) ការធ្វើទំនាក់ទំនងរបស់

---

[1] *ករណីរបស់ អៀង សារី,* បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ និងសំណើសុំដាក់កាលបរិច្ឆេទដាក់ឯកសារជាបន្ទាន់ និងសវនាការផ្ទាល់មាត់ជាសាធារណៈ, ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩, D138/1/1, ERN 00287360-00287378 [*ចាប់ពីនេះតទៅហៅថា* បណ្ដឹងឧទ្ធរណ៍] ។

[2] *ករណីរបស់ អៀង សារី,* ដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩, D138, ERN 00284977-00284983 [*ចាប់ពីនេះតទៅហៅថា* ដីកាសម្រេចអំពីភាពសម្ងាត់] ។

[3] ដីកាសម្រេចអំពីភាពសម្ងាត់, ទំព័រទី៧ ។

សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ មិនបានរួមបង្កើតជា "សេចក្តីសម្រេច" ណាមួយទេ និងទោះបីក្នុងករណីណាក៏ដោយ វាមិនស្មើគ្នានឹង "ការព្រមាន" តាមផ្លូវច្បាប់ណាមួយដែរ វៀរលែងតែបន្ទាប់ពីមានដំណើរការនីតិវិធីដែលអាចនឹងត្រូវចាប់ផ្តើមធ្វើឡើងប្រឆាំងនឹងមេធាវីការពារក្តី និង (៤) ការផ្សព្វផ្សាយនូវឯកសារមួយចំនួនណាមួយតាមការជ្រើសរើសដោយអង្គតុលាការនេះ បង្ហាញឱ្យឃើញពី "ការរើសអើងនៅក្នុងការប្រព្រឹត្តិ" ប្រឆាំងនឹងមេធាវីការពារក្តី[4] ។

## ២. សេចក្តីសង្ខេបនៃអំណះអំណាង

៣. សហព្រះរាជអាជ្ញាសង្កេតឃើញថា អង្គបុរេជំនុំជម្រះអាចពិចារណាដោយច្រានចោលបណ្តឹងឧទ្ធរណ៍នេះ ដោយសារតែភាពខ្វះខាតខាងសិទ្ធិប្តឹងរបស់ដើមបណ្តឹងឧទ្ធរណ៍ អៀង សារី ។ ដីកាសម្រេចអំពីភាពសម្ងាត់ ត្រូវបានចេញ ស្របតាមវិធាន៣៥ និងវិធាន៣៨ នៃវិធានផ្ទៃក្នុង ("វិធាន") ប្រឆាំងទៅលើតែមេធាវីការពារក្តីតែប៉ុណ្ណោះ ។ អាស្រ័យហេតុនេះ ដើមបណ្តឹងឧទ្ធរណ៍ អៀង សារី មិនមានសិទ្ធិដាក់បណ្តឹងឧទ្ធរណ៍នេះទេ ហើយដីកាសម្រេចលើភាពសម្ងាត់ ក៏មិនបានផ្តល់សំអាងនៃបណ្តឹងដើម្បីដាក់ស្នើទៅអង្គបុរេជំនុំជម្រះដែរ ។ ទោះបីដើមបណ្តឹងឧទ្ធរណ៍ មានសិទ្ធិប្តឹង និងសំអាងនៃបណ្តឹងក៏ដោយ បណ្តឹងឧទ្ធរណ៍នេះក៏មិនត្រូវបានអនុញ្ញាតដែរ យោងតាមវិធាន៧៤.៣ ដែលបានរៀបរាប់គ្មានសល់ពីប្រភេទនៃបណ្តឹងឧទ្ធរណ៍ដែលជនត្រូវចោទអាចនាំមកនៅចំពោះមុខអង្គបុរេជំនុំជម្រះ ។

៤. បើសិនអង្គបុរេជំនុំជម្រះពិចារណាឃើញថា បណ្តឹងឧទ្ធរណ៍នេះ បាននិងកំពុងស្នើឡើងដោយមេធាវីការពារក្តីតាមសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ នោះវាលើកឡើងនូវបញ្ហាច្បាប់ដ៏សំខាន់ទាក់ទងនឹងតម្លាភាព និងភាពត្រឹមត្រូវនៃដំណើរការនីតិវិធីនៅចំពោះមុខតុលាការនេះ ។ ជាពិសេស បណ្តឹងឧទ្ធរណ៍បានលើកឡើងឱ្យមានសំណួរពីរ សម្រាប់ធ្វើការកំណត់ដោយអង្គបុរេជំនុំជម្រះ ។ សំណួរទាំងពីរនោះគឺ (១) តើអ្វីទៅដែលជាភាពស្របគ្នានៃគោលការណ៍អំពីភាពសម្ងាត់នៃដំណើរការនីតិវិធីមុនពេលជំនុំជម្រះ និងរបៀប ព្រមទាំងវិសាលភាព ដែលព័ត៌មាន

[4] បណ្តឹងឧទ្ធរណ៍, ទំព័រទី៥ ។

អ្វីខ្លះដែលអាចផ្សព្វផ្សាយដោយតុលាការនេះ ឬគូភាគីនានា និង (២) ថាតើនៅក្រោមកាលៈទេសៈណាដែលបុគ្គលណាម្នាក់ ជាពិសេស មេធាវីការពារក្តីដែលមានអាណត្តិការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ចុងចោទ អាចត្រូវបានដាក់ទណ្ឌកម្មដោយតុលាការនេះ ចំពោះអំពើដែលគេបានអះអាងថា បានធ្វើឡើងដើម្បីពន្លឿនសិទ្ធិដូចគ្នាទាំងនោះ ។

## ៣. ចរិតលក្ខណៈនៃសេចក្តីសង្កេតនាំងនេះ

៥. បញ្ហានៃការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលយុត្តិធម៌ ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងការប្រមាថមាននៅក្នុងយុត្តាធិការជាតិ និងអន្តរជាតិមួយចំនួន គឺជាបញ្ហាច្រើនតែមានរវាងតុលាការ និងជនល្មើសដែលបានចោទប្រកាន់[5] ។ ហេតុដូចនេះ សហព្រះរាជអាជ្ញាមិនពិចារណាខ្លួនឯងថា ជាគូភាគីពេញលេញចំពោះដំណើរការនីតិវិធីទាំងនេះទេ ប៉ុន្តែគ្រាន់តែជា "ភាគីដែលចាប់អារម្មណ៍" ជាមន្ត្រីនៃតុលាការនេះ[6] ។ តាមតួនាទីមានកំរិតក្នុងបណ្តឹងឧទ្ធរណ៍នេះ និងវិសាលភាពចំពោះផលវិបាកដ៏តូចចង្អៀតនៃសេចក្តីសង្កេតនេះ សហព្រះរាជអាជ្ញាមិនឈរលើគោលជំហរណាមួយអំពីអង្គហេតុទាំងអស់ក្នុងសារណា ដែលបានធ្វើឡើងដោយដើមបណ្តឹងឧទ្ធរណ៍នេះទេ លើកលែងអ្វីដែលសហព្រះរាជអាជ្ញាលើកឡើងផ្ទាល់ក្នុងសេចក្តីសង្កេតនេះ ។

## ៤. សេចក្តីសង្កេតបឋម

### *បណ្តឹងឧទ្ធរណ៍អាចនឹងត្រូវបានច្រានចោលដោយសារកង្វះសិទ្ធិប្តឹង និងសំអាងនៃបណ្តឹង*

---

[5] *រដ្ឋអាជ្ញា ទល់នឹង Aleksovski,* សាលក្រមលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ Anto Nobilo ប្រឆាំងនឹងការរកឃើញនូវការប្រមាថ, សំណុំរឿងលេខ: IT-95-14/1-AR77, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ចុះថ្ងៃទី៣០ ឧសភា ២០០១, កថាខ័ណ្ឌទី២៤ [*ចាប់ពីនេះតទៅហៅថា* សាលក្រម Aleksovski] ។ *Laxmi Narayan ទល់នឹង D.D.A,* សាលក្រមចុះថ្ងៃទី១២ កក្កដា ២០០៤, តុលាការជាន់ខ្ពស់ទីក្រុងញូដេលី នៅទីក្រុងញូដេលី, កថាខ័ណ្ឌទី៥ ។

[6] *រដ្ឋអាជ្ញា ទល់នឹង Dusko Tadic,* សាលក្រមលើបណ្តឹងឧទ្ធរណ៍ស្តីពីការចោទប្រកាន់អំពីការប្រមាថ ប្រឆាំងនឹងមេធាវីពីមុន, Milan Vujin, ចុះថ្ងៃទី២៧ កុម្ភៈ ២០០១, សំណុំរឿងលេខ: IT-94-1-A-AR77, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ទំព័រទី១,[*ចាប់ពីនេះតទៅហៅថា* សេចក្តីសម្រេចអំពីការប្រមាថ Tadic] ។ នៅក្នុងសំណុំរឿងនេះ ការប្រមាថប្រឆាំងនឹងអតីតមេធាវីការពារក្តីម្នាក់, ជនជាប់ចោទបានដាក់សារណាតប ក្នុងនាមជា "ភាគីដែលមានផលប្រយោជន៍" ខណៈដែលការចោទប្រកាន់មិនបានបើកសវនាការ ។

៦. បណ្តឹងឧទ្ធរណ៍នេះ បានដាក់ដោយជនត្រូវចោទអៀង សារី[7] ។ អៀង សារី គ្មានសិទ្ធិប្តឹងដើម្បីដាក់បណ្តឹងឧទ្ធរណ៍នេះទេ ហើយដីកាសម្រេចលើភាពសម្ងាត់ក៏មិនបានផ្តល់ឱ្យគាត់នូវសំអាងនៃបណ្តឹងដើម្បីដាក់បណ្តឹងឧទ្ធរណ៍នេះដែរ ។ ដីកាសម្រេចលើភាពសម្ងាត់មិនបានចេញដោយប្រឆាំងនឹងអៀង សារីទេ ។ បណ្តឹងឧទ្ធរណ៍មិនបានបង្ហាញថា គាត់បានទទួលរងនូវភាពលំអៀង ឬ ការបដិសេសនូវសិទ្ធិណាមួយដែលចាំបាច់ត្រូវមានការដោះស្រាយ ដោយអង្គបុរេជំនុំជម្រះ តាមការប្តឹងឧទ្ធរណ៍ឡើយ ។

៧. ទោះបីដើមបណ្តឹងឧទ្ធរណ៍មានសិទ្ធិប្តឹង និងសំអាងនៃបណ្តឹងក៏ដោយ ក៏បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានដែរ នៅក្រោមវិធាន៧៤.៣ ដែលបានរៀបរាប់គ្មានសល់អំពីប្រភេទនៃបណ្តឹងឧទ្ធរណ៍ដែលជនត្រូវចោទអាចនាំមកចំពោះមុខអង្គបុរេជំនុំជម្រះ[8] ។ ដីកាសម្រេចលើភាពសម្ងាត់ បានធ្វើទៅលើមេធាវីការពារក្តីដោយផ្ទាល់[9] ។ ហេតុដូចនេះ បណ្តឹងឧទ្ធរណ៍នេះអាចនឹងត្រូវបានច្រានចោលដោយសារ (១) ចង់មានសិទ្ធិប្តឹង និងសំអាងនៃបណ្តឹង ហើយទោះបីនៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ (២) ដោយសារមិនអាចទទួលយកបាននៅក្រោមវិធាន ៧៤.៣ ។ តាមរបៀបផ្សេងពីនេះ អង្គជំនុំជម្រះអាចពិចារណាច្រានចោលបណ្តឹងឧទ្ធរណ៍នេះដោយមិនធ្វើឱ្យខូចដល់ដើមបណ្តឹងឧទ្ធរណ៍ ។ មេធាវីការពារក្តីអាចនឹងត្រូវបានគេទុកឱ្យស្វះស្វែងរកឧបាស្រ័យចំពោះដំណោះស្រាយបែបដូច្នេះ ព្រោះវាអាចនឹងរកបាននៅក្រោមច្បាប់ ។

## ***ការកំណត់ពេលច្បាស់លាស់អំពីការដាក់ឯកសារមិនត្រូវទេ***

---

[7] បណ្តឹងឧទ្ធរណ៍, ទំព័រក្របមុខ (ដែលនិយាយថា "បណ្តឹងឧទ្ធរណ៍របស់អៀង សារី ....") ។ បណ្តឹងឧទ្ធរណ៍នេះ ត្រូវបានចុះហត្ថលេខាដោយមេធាវីការពារក្តីក្នុងនាមជា "សហមេធាវីការពារក្តីឱ្យលោក អៀង សារី" (បណ្តឹងឧទ្ធរណ៍, ទំព័រទី១៨) ។ បណ្តឹងឧទ្ធរណ៍គូសបញ្ជាក់ជាដដែលៗទៅលើសេចក្តីយោងនៃសេចក្តីសន្និដ្ឋាន ក្នុងនាម "មេធាវីការពារក្តី" របស់ អៀង សារី (បណ្តឹងឧទ្ធរណ៍ កថាខ័ណ្ឌទី១, ១២, ១៧, ២៨,៣១, ៣៧ ។ល។)

[8] *ករណីរបស់ អៀង សារី*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩, A190/II/9, ERN 0023298-00283310, កថាខ័ណ្ឌទី ២៨ ។

[9] ដីកាសម្រេចអំពីភាពសម្ងាត់, ទំព័រទី៧ ។

៨. ដើមបណ្តឹងឧទ្ធរណ៍មិនបានលើកយោងនូវបទប្បញ្ញត្តិច្បាប់ណាមួយ ឬបានយោងអំពីករណីយុត្តិសាស្ត្រ ដើម្បីស្វែងរកឱ្យមានការកំណត់ពេលច្បាស់លាស់សម្រាប់គូភាគីនានាដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍នេះ និងបណ្តឹងឧទ្ធរណ៍ដែលត្រូវបើកសវនាការនៅថ្ងៃទី ៣ ខែមេសា ឆ្នាំ២០០៨ ទេ ។ គាត់គ្រាន់តែបានអះអាងថា "គាត់ [បានដាក់បណ្តឹងឧទ្ធរណ៍] នៅក្នុងសប្តាហ៍ដែលមានការជូនដំណឹងអំពី [ដីកាសម្រេច] នោះ"[10] ។ សេចក្តីសម្រេចជាឯកតោភាគីរបស់ភាគីដាក់ពាក្យបណ្តឹងនេះ ដោយគ្មានទឡ្ហីករណ៍បញ្ជាក់ពីភាពបន្ទាន់ គឺច្បាស់ណាស់ថា ទាំងពាក្យបណ្តឹង និងទាំងខ្លឹមសារក្នុងពេលបណ្តឹងនេះផង មិនអាចជាយុត្តិកម្ម សម្រាប់បង្ខំភាគីម្ខាងទៀតឱ្យដាក់ចម្លើយតបរបស់ខ្លួន ឱ្យបានមុនពេលវេលាដែលបានកំណត់ដោយច្បាប់បានឡើយ ។

៩. នៅក្នុងបរិយាកាសមួយដែលប្រើបីភាសា ដូចតុលាការនេះ ដែលពឹងផ្អែកទៅលើកិច្ចសហការ និងការពិគ្រោះយោបល់ផ្សេងៗរវាងបុគ្គលិកជាតិ និងអន្តរជាតិ ត្រូវតែមានពេលវេលាសមរម្យសម្រាប់ការពិគ្រោះយោបល់ និងការធ្វើសេចក្តីព្រាងជាបន្តបន្ទាប់ និងការបកប្រែសរសេរលើសារណាច្បាប់នានា ។ អាស្រ័យហេតុនេះការអនុវត្តន៍ណាមួយដែលនាំដល់ការពន្យាពេលវេលា ដូចបានកំណត់នៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ដែលបានជជែកវែកញែក និងកំណត់យ៉ាងប្រុងប្រយ័ត្ន ត្រូវតែពឹងផ្អែកទៅលើការបង្ហាញឱ្យឃើញពីកាលៈទេសៈលើកលែងជាពិសេស[11] ។ ការបង្ហាញដូចនេះ មិនមានទេនៅទីនេះ ហើយដើមបណ្តឹងឧទ្ធរណ៍ក៏មិនបានស្វែងរកការជួសជុល *ដោយភាគីតែម្ខាង* ឬ *ដោយបណ្តោះអាសន្ន* ដើម្បីជាយុត្តិកម្មចំពោះការកំណត់ពេលវេលាច្បាស់លាស់ ។ ហេតុដូច្នេះ និងជាការសមរម្យ អង្គបុរេជំនុំជម្រះមិនអនុញ្ញាតឱ្យមានការកំណត់ពេលច្បាស់លាស់ណាមួយទេ[12] ។

---

[10] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី៨ ។

[11] សេចក្តីណែនាអនុវត្តស្តីពីការដាក់ឯកសារ, អ.វ.ត.ក/០១/២០០៧/ច្បាប់វិសោធនកម្មលើកទី៣ [*ចាប់ពីនេះតទៅហៅថា* សេចក្តីណែនាំអនុវត្ត] ។

[12] *ករណីរបស់ អៀង សារី*, សេចក្តីបង្គាប់ដល់ភាគី ទាក់ទងនឹងសំណើរបស់ អៀង សារី សុំដាក់កាលបរិច្ឆេទដាក់ឯកសារជាបន្ទាន់ និងសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ ចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការរំលោភបំពានលើការសម្ងាត់នៃកិច្ចស៊ើបសួរ, D138/1/2, ERN 00287681-00287682 ។

## សវនាការផ្ទាល់មាត់

១០. ដើមបណ្តឹងឧទ្ធរណ៍ ស្វែងរកឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈមួយ នៅលើបណ្តឹងឧទ្ធរណ៍នេះ បើយោងតាមគាត់ លើកឡើងអំពី "បញ្ហាជាមូលដ្ឋាន [ដែល] ទំនងជាមានផលប៉ះពាល់ដល់ការសម្រេច និងភាពជឿជាក់ លើលទ្ធផលចុងក្រោយនៃដំណើរការនីតិវិធីរបស់ អ.វ.ត.ក"[13] ។ សហព្រះរាជអាជ្ញាសង្កេតឃើញថា សិទ្ធិទទួលបានការជំនុំជម្រះ មិនចាំបាច់មានន័យថា ទាល់តែមានសវនាការផ្ទាល់មាត់ទេ វាអាចដាក់បញ្ចូលនូវការសម្រេចមួយដែលមានសំអាងហេតុ និងជាសាធារណៈ នៅលើសេចក្តីថ្លែងសំអាងជាលាយល័ក្ខអក្សរមួយក៏បាន[14] ។ ប្រសិនបើគូភាគីនានាត្រូវបានផ្តល់នូវឱកាសទូលំទូលាយដើម្បីបញ្ជូនករណីរបស់ខ្លួនជាលាយល័ក្ខអក្សរនិងដើម្បីផ្តល់យោបល់នៅលើសារណារបស់ភាគីផ្សេងទៀត អង្គជំនុំជម្រះមួយអាច ឃើញថា លក្ខខណ្ឌតម្រូវអំពីភាពត្រឹមត្រូវត្រូវបានគេអនុវត្តតាម ហើយសវនាការផ្ទាល់មាត់មួយមិនចាំបាច់ទេ[15] ។

១១. ខណៈបញ្ហានៅក្នុងបណ្តឹងឧទ្ធរណ៍នេះជាបញ្ហាសំខាន់ ការសម្រេចបញ្ចប់លើបណ្តឹងឧទ្ធរណ៍អំពីសេចក្តីថ្លែងសំអាងជាលាយល័ក្ខអក្សរតែមួយមុខ មិនអាចថា ជាសាធារណៈតិចតួចជាង ឬមានតម្លាភាពតិចតួចឡើយ ប្រសិនបើការដាក់ឯកសារ និងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ត្រូវបានគេដាក់ឱ្យរកបាននៅលើកម្មសិទ្ធិសាធារណៈរួចទៅហើយនោះ ។ វាបានក្លាយជាការអនុវត្តន៍របស់អង្គបុរេជំនុំជម្រះដែលថា រាល់ឯកសាររបស់ភាគីទាំងអស់ដែលបានដាក់ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍នៅចំពោះមុខខ្លួន និងសេចក្តីសម្រេចជាបន្តបន្ទាប់ ត្រូវបានដាក់ផ្សាយនៅលើវិបសាររបស់ អ.វ.ត.ក ។ អង្គបុរេជំនុំជម្រះកម្រគេចចេញពីការអនុវត្តន៍បែបនេះណាស់ វៀរលែងតែផលប្រយោជន៍របស់គូភាគី (ជាពិសេស ចុងចោទ) ត្រូវទទួលនូវការ

---

[13] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី១១ ។

[14] *Jussila ទល់នឹងប្រទេស Findland*, សាលក្រម ចុះថ្ងៃទី២៣ វិច្ឆិកា ២០០៦, សំណើលេខ: No. 73053/01, អង្គជំនុំជម្រះខ្នាតធំនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប, កថាខ័ណ្ឌទី៤១ ។

[15] *Vilho Eskelinen និងគូកន ទល់នឹងប្រទេស Findland*, សាលក្រម ចុះថ្ងៃទី១៩ មេសា ២០០៧, សំណើលេខ: No. 63235/00, អង្គជំនុំជម្រះខ្នាតធំនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប, កថាខ័ណ្ឌទី៧៤ ។

ប៉ះពាល់[16] ។ តុលាការអន្តរជាតិ ដែលធ្វើការកាត់សេចក្តីលើបទឧក្រិដ្ឋដែលមានទំហំ និងភាពចម្រុះស្រដៀងគ្នានឹងតុលាការនេះដែរតែងតែធ្វើការសម្រេចយ៉ាងទៀងទាត់លើបណ្តឹងឧទ្ធរណ៍អំពីតែសេចក្តីថ្លែងជាលាយល័ក្ខអក្សរតែមួយមុខគត់ ។ ជាការពិតណាស់តុលាការទាំងនេះ ក៏បានច្រានចោលពាក្យសុំឱ្យមានសវនាការផ្ទាល់មាត់ ដោយផ្អែកទៅលើតែទឡ្ហីករណ៍នៃ "ភាពចម្រុះនៃបញ្ហា" តែមួយមុខប៉ុណ្ណោះ[17] ។

១២. ការអនុវត្តន៍ច្បាស់លាស់ និងស៊ីសង្វាក់គ្នាមួយបានលេចឡើង ទាក់ទិននឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដើម្បីឱ្យមានសវនាការផ្ទាល់មាត់ ។ អង្គបុរេជំនុំជម្រះបានបើកសវនាការផ្ទាល់មាត់ទាំងអស់ ប៉ុន្តែមានបណ្តឹងឧទ្ធរណ៍មួយទាក់ទងនឹងការឃុំខ្លួន[18] ហើយបណ្តឹងឧទ្ធរណ៍បែបនេះ អាចនឹងនាំឱ្យមានការផុតរលត់នៃដំណើរការនីតិវិធី និងការដោះលែងចុងចោទម្នាក់ជាយថាហេតុ[19] ។ ហេតុដូច្នេះ ជាសរុប សេរីភាពរបស់ចុងចោទម្នាក់ គឺជាឧត្តមភាពនៃការពិចារណានៅក្នុងការកំណត់របស់អង្គបុរេជំនុំជម្រះ ថាតើត្រូវមានសវនាការផ្ទាល់មាត់ឬទេ[20] ។

---

[16] *ករណីរបស់ អៀង សារី,* សេចក្តីសម្រេចដោយអនុលោមតាមវិធាន៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារៈ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ចំពោះការតែងតាំងអ្នកជំនាញ, ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨, A189/1/6, ERN 00207784-00207785, កថាខ័ណ្ឌទី៤ ។

[17] *រដ្ឋអាជ្ញា ទល់នឹង Marijacic,* សាលក្រម, សំណុំរឿងលេខ: IT-95-14-R77.2-A, ចុះថ្ងៃទី២៧ កញ្ញា ២០០៦, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, កថាខ័ណ្ឌទី៩-១០ [*ចាប់ពីនេះតទៅហៅថា* សាលក្រម Marijacic] ។

[18] អង្គបុរេជំនុំជម្រះបានបើកសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ដើមប្រឆាំងការឃុំខ្លួនចំនួនប្រាំរួចហើយ នៃជនជាប់ឃុំទាំងប្រាំនាក់នៃតុលាការនេះ ។ ចាប់ពីពេលនោះមក បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តការឃុំខ្លួនរបស់ អៀង ធីរិទ្ធ ក៏បានធ្វើសន្និដ្ឋានបញ្ចប់ ហើយក៏កំពុងស្ថិតក្នុងដំណើរការនៃសវនាការផ្ទាល់មាត់លើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តការឃុំខ្លួនរបស់ ខៀវ សំផន និងអៀង សារី ។ តាមការព្រមព្រៀងរបស់ភាគី បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តការឃុំខ្លួនរបស់ នួន ជា ត្រូវបានរំពឹងទុកថា នឹងមានការសម្រេចទៅលើតែសេចក្តីថ្លែងសំអាងជាលាយល័ក្ខណ៍អក្សរតែមួយមុខគត់ ។

[19] *ករណីរបស់ ខៀវ សំផន,* សេចក្តីសម្រេចលើពាក្យសុំឱ្យមានសវនាការជាសាធារណៈ របស់ ខៀវ សំផន, ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨, A190/1/8, ERN 00226251-00226254, កថាខ័ណ្ឌទី៨ ។ ការណ៍នេះ ឆ្លុះបញ្ចាំងទៅលើវិធាន៧៧.៦ ដែលថា សវនាការជាសាធារណៈអាចត្រូវបានធ្វើឡើង "ជាពិសេស ប្រសិនបើករណីនាំដល់ការបញ្ចប់ដោយសេចក្តីសម្រេចរបស់ [អង្គបុរេជំនុំជម្រះ]" ។

[20] *ករណីរបស់ ខៀវ សំផន,* សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដើម្បីកំណត់លើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយល័ក្ខណ៍អក្សរតែប៉ុណ្ណោះ និងដីកាកំណត់កាលបរិច្ឆេទសវនាការ, ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៩, C26/5/13, ERN 0027631-0027633 ។

១៣. ដើមបណ្ដឹងឧទ្ធរណ៍បានតវ៉ាទាំងមានកំហុសឆ្គងថា លក្ខណៈវិនិច្ឆ័យចំនួនពីរ ដែលបានអនុម័ត ដោយអង្គបុរេជំនុំជម្រះ គឺ (១) សារសំខាន់ចំពោះបញ្ហាដែលពាក់ព័ន្ធ និង(២) មតិ ឬការយល់ព្រមរបស់គូភាគី[21] ។ ដូចដែលកត្តាទាំងនេះ ត្រូវបានលើកយកទៅពិចារណាដោយអង្គបុរេជំនុំជម្រះនៅពេលធ្វើការសម្រេចអំពីការបើកសវនាការផ្ទាល់មាត់ វាមិនមែនជាលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់តែមួយគត់ទេ ។ អង្គបុរេជំនុំជម្រះបានកំណត់ជាទៀងទាត់ លើបណ្ដឹងឧទ្ធរណ៍ដោយលើកយកនូវខ្លឹមសារសំខាន់ៗនៃបញ្ហា នៅលើសារណាជាលាយល័ក្ខអក្សរតែមួយគត់ ។ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាដំណោះស្រាយលើករណីខុច ដើមបណ្ដឹងឧទ្ធរណ៍នេះ និងបណ្ដឹងឧទ្ធរណ៍របស់ នួន ជា ស្ដីពីការចាត់តាំងអ្នកជំនាញបញ្ជាក់អំពីភាពសមស្រប និងលក្ខខណ្ឌនៃការឃុំខ្លួន បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងឧទ្ធរណ៍អំពីសិទ្ធិនៃការបកប្រែឯកសារ និងបណ្ដឹងដិតចិត្តចំពោះបុគ្គលិកសហចៅក្រមស៊ើបអង្កេត ទាំងអស់សុទ្ធតែបានត្រូវកំណត់នៅលើតែសេចក្ដីថ្លែងជាលាយល័ក្ខអក្សរតែមួយមុខប៉ុណ្ណោះ ។ បណ្ដឹងឧទ្ធរណ៍ទាំងអស់នេះ តាមពិតគឺគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់នៅចំពោះមុខអង្គបុរេជំនុំជម្រះ បានលើកឡើងពីបញ្ហាសំខាន់ៗ ។ ជាការបន្ថែម អង្គជំនុំជម្រះតុលាការមួយមានសមាសភាគចៅក្រមវិជ្ជាជីវៈ (មិនមែនជាសមាជិកគណៈវិនិច្ឆ័យ ឬ ចៅក្រមគ្មានអាជីព ឬ បណ្ដុំនៃចៅក្រមអាជីព និងគ្មានអាជីព) អាចធ្វើការដោះស្រាយយ៉ាងគ្រប់គ្រាន់ជាមួយបណ្ដឹងឧទ្ធរណ៍មួយដោយលើកឡើងពីបញ្ហាសំខាន់ៗតែមួយមុខគត់នៅលើមូលដ្ឋាននៃសារណាជាលាយល័ក្ខអក្សរដោយមិនចាំបាច់ឲ្យមានសវនាការផ្ទាល់មាត់ ។ នៅក្នុងការសម្រេចនេះ ខណៈដែលអង្គបុរេជំនុំជម្រះ តម្រូវឲ្យ "[ពិចារណា] លើទស្សនៈផ្សេងៗរបស់គូភាគី" ក៏ដោយ តែនេះមិនចងនូវកាតព្វកិច្ច ដោយទស្សនៈរបស់ភាគីដែលដាក់សំណើទេ[22] ។

១៤. ហេតុដូចនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គបុរេជំនុំជម្រះ ពិចារណាលើយុត្តិសាស្ត្រ និងការអនុវត្តន៍នេះ នៅពេលធ្វើការសម្រេចថាតើ ត្រូវមានសវនាការផ្ទាល់មាត់នៃបណ្ដឹងឧទ្ធរណ៍នេះដែរឬទេ ។

---

[21] បណ្ដឹងឧទ្ធរណ៍, កថាខ័ណ្ឌទី១០ ។

[22] វិធាន៧៧.៣.ខ នៃវិធានផ្ទៃក្នុង, [*ចាប់ពីនេះតទៅហៅថា* វិធាន] ។

## ៥. សេចក្តីសន្និដ្ឋានជាសារធាតុ

១៥. ប្រសិនបើអង្គបុរេជំនុំជម្រះពិចារណាថា បណ្តឹងឧទ្ធរណ៍នេះ ត្រូវបានធ្វើឡើងដោយមេធាវីការពារក្តីតាមសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ នោះសហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះ ចោទនូវសំណួរពីរដ៏សំខាន់សម្រាប់ជាការសម្រេចរបស់អង្គបុរេជំនុំជម្រះ ។ សំណួរទាំងពីរនោះគឺ (១) តើអ្វីទៅដែលជាភាពស្របគ្នានៃគោលការណ៍អំពីភាពសម្ងាត់នៃដំណើរការនីតិវិធីមុនពេលជំនុំជម្រះ និងរបៀប ព្រមទាំងវិសាលភាពដែលព័ត៌មានអ្វីខ្លះដែលអាចផ្សព្វផ្សាយដោយតុលាការនេះ ឬគូភាគីនានានៃដំណើរការនីតិវិធីរបស់ខ្លួន និង(២) ថាតើនៅក្រោមកាលៈទេសៈណាដែលបុគ្គលណាម្នាក់ ជាពិសេស មេធាវីការពារក្តីដែលមានអាណត្តិការពារសិទ្ធិទទួលបាននូវការជំនុំជម្រះត្រឹមត្រូវរបស់ចុងចោទ អាចត្រូវបានដាក់ទណ្ឌកម្មដោយតុលាការនេះ ចំពោះអំពើដែលគេបានអះអាងថាបានធ្វើឡើងដើម្បីពន្លឿនសិទ្ធិដូចគ្នាទាំងនោះ ។ សំណួរទាំងនេះ គឺមានការជាប់ទាក់ទងគ្នាទៅវិញទៅមក និងនៅក្នុងបរិបទពិសេសនៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវតែបានដោះស្រាយតាមលំដាប់លំដោយដូចមាននៅក្នុងសេចក្តីសង្កេតនេះ ។

### ក. ការសម្ងាត់នៃកិច្ចដំណើរការនីតិវិធី និងការបង្ហាញដែលអាចទទួលយកបាននៅមុនពេលជំនុំជម្រះ

គោលការណ៍ជាមូលដ្ឋាននៃការគ្រប់គ្រងកិច្ចដំណើរការនីតិវិធីរបស់តុលាការនេះ អំពីការសម្ងាត់

១៦. ក្នុងពេលបង្កើតតុលាការកូនកាត់ពិសេសនេះឡើង ដែលមានអាណត្តិពិសេសប្លែកពីគេ អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា បានព្រមព្រៀង (“កិច្ចព្រមព្រៀង”) ថា តុលាការនេះត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន ស្របទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ មានភាពត្រឹមត្រូវ និងក្នុងដំណើរការច្បាប់សមរម្យ ដូចបានកំណត់នៅក្នុងមាត្រា១៤និងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ICCPR”)[23] ។ កិច្ចព្រមព្រៀងនេះមានការរំពឹងគិតទុកថាដើម្បីជាផលប្រយោជន៍នៃ “ការធានាឲ្យមានភាពត្រឹមត្រូវ និងសវនាការជាសា

---

[23] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣, មាត្រា១២.២ [*ចាប់ពីនេះតទៅហៅថា* កិច្ចព្រមព្រៀង] ។

ធារណៈ និងការជឿទុកចិត្តលើនីតិវិធី” សហគមន៍អន្តរជាតិ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអង្គការមិនមែនរដ្ឋាភិបាលត្រូវ “មានលទ្ធភាពទទួលបានអំពីដំណើរការនីតិវិធីគ្រប់ពេលទាំងអស់” របស់តុលាការនេះ ។ ការហាមឃាត់ណាមួយចំពោះអង្គភាពមិនឲ្យចូលរួមនៅក្នុងដំណើរការនីតិវិធីទាំងនេះ “អាចធ្វើទៅបានលើកលែងតែមានភាពចាំបាច់តឹងរ៉ឹងបំផុត” ដែលសាធារណភាពនេះ នឹងធ្វើឲ្យខូចដល់ផលប្រយោជន៍យុត្តិធម៌តែប៉ុណ្ណោះ”[24] ។ កិច្ចព្រមព្រៀងនេះ អនុវត្តដូចជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងចងកាតព្វកិច្ចចំពោះតុលាការនេះ[25] ។

១៧. មាត្រា១៤ នៃ ICCPR ដែលនៅជាធរមានចំពោះតុលាការនេះ មាន “សិទ្ធិទទួលបានសវនាការដោយយុត្តិធម៌” ជាអប្បបរមា របស់ចុងចោទនៅចំពោះមុខតុលាការនេះ[26] ។ ពាក្យថា “សិទ្ធិទទួលបានសវនាការដោយយុត្តិធម៌” ត្រូវបានក្លាយទៅជាពាក្យសិល្បៈមួយ ហើយពាក្យនេះមិនចាំបាច់សំដៅទៅលើសិទ្ធិទទួលបានដោយចុងចោទ តែនៅពេលសវនាការទេ ។ ជាការពិត “សិទ្ធិទទួលបានសវនាការដោយយុត្តិធម៌” ជាច្រើនដូចជាសិទ្ធិទទួលបានមេធាវីការពារក្តី សិទ្ធិមិនផ្តល់សក្ខីកម្ម សិទ្ធិសន្មតថាគ្មានទោស ចាំបាច់ត្រូវប្រើក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ និងមុនពេលជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការនេះ ។ ស្របគ្នានេះដែរ ដោយស្រង់មាត្រា៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“ច្បាប់អ.វ.ត.ក”) អង្គបុរេជំនុំជម្រះបានកត់សំគាល់ថាចុងចោទនៅចំពោះមុខតុលាការនេះ មានសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ចាប់តាំងពីដើមដំបូងនៃកិច្ចស៊ើបសួរមកម្ល៉េះ”[27]។ ស្រដៀងគ្នានេះដែរ តុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”) ដែលក្នុងដំណាក់កាលនៃកិច្ចស៊ើបសួររបស់ខ្លួនគ្មានអ្វីដែលថាមិនស្រដៀងគ្នាជាសំខាន់នឹងតុលាការនេះទេ បានសម្រេចថា ការធានាឲ្យមានសវនាការដោយយុត្តិធម៌ មិនកំរិតត្រឹមសវនាការប៉ុណ្ណោះទេ ប៉ុន្តែវាពង្រីករហូតដល់

---

[24] មាត្រា១២.២ នៃ កិច្ចព្រមព្រៀង ។

[25] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ច្បាប់វិសោធនកម្មអនុលោមតាមកិច្ចព្រមព្រៀង, ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០០៤, នស/រកម/១០០៤/០០៦, មាត្រា៤៧ថ្មីស្ទួន [*ចាប់ពីនេះតទៅហៅថា* ច្បាប់អ.វ.ត.ក] ។

[26] មាត្រា៣៥ថ្មី នៃច្បាប់អ.វ.ត.ក ។

[27] *ករណីរបស់ នួន ជា*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ចំពោះការចាត់តាំងអ្នកជំនាញ, D54/5/6, ERN 00233617-00233627, កថាខ័ណ្ឌទី២៥ ។

ដំណើរការផ្សេងៗនៃកិច្ចដំណើរការនីតិវិធីសវនាការ ជាការពិតណាស់ វាពង្រីកដល់គ្រប់ទិដ្ឋភាពទាំងអស់នៃកិច្ចដំណើរការនីតិវិធី[28] ។

១៨. ដូចដែលច្បាប់អ.វ.ត.ក និងកិច្ចព្រមព្រៀង គឺជាឯកសារស្ថាបនិកនៃតុលាការនេះ វិធានផ្ទៃក្នុងដែលបានតាក់តែងឡើងដោយអង្គចៅក្រមរបស់ខ្លួន ដោយបញ្ចូលច្បាប់នីតិវិធីជាធរមានចំពោះមុខតុលាការនេះ ទុកដូចជាអាណត្តិការងារ ដូចបានកំណត់នៅក្រោមមាត្រា១២.១ នៃកិច្ចព្រមព្រៀង និងមាត្រា២០ថ្មី មាត្រា២៣ថ្មី និងមាត្រា៣៣ថ្មី នៃច្បាប់អ.វ.ត.ក[29] ។ ហេតុដូច្នេះស្មារតីនៃកិច្ចព្រមព្រៀង និងច្បាប់អ.វ.ត.ក ត្រូវតែធ្វើឲ្យជ្រួតជ្រាបទៅក្នុងវិធានផ្ទៃក្នុង ។ ភាពស៊ីសង្វាក់គ្នាទៅនឹងស្មារតីនេះ និងដោយសារ "ភាពជាក់លាក់ដែលជាប់មកជាមួយស្រាប់" របស់តុលាការនេះ វិធាន២១.១ បានកំណត់យ៉ាងតឹងតែងនូវ "គោលការណ៍ជាសារវ័ន្ត" ដូចខាងក្រោមនេះ ៖

១. គ្រប់ឯកសារមូលដ្ឋានទាំងអស់ចំពោះមុខតុលាការនេះ (រួមទាំង វិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្ត) ត្រូវតែបកស្រាយ "ក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ [ចុងចោទ] និងជនរងគ្រោះ និងដើម្បីធានាអំពី [...] និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព"[30] ។

២. កិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការនេះ ត្រូវតែ "មានយុត្តិធម៌ និងត្រូវតែគោរពគោលការណ៍ចំពោះមុខ"[31] ។

---

[28] *ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ករណី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo,* សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ប្រឆាំងនឹង សេចក្តីសំរេចរបស់អង្គជំនុំជម្រះសាលាដំបូង I ដែលមានចំណងជើងថា "សេចក្តីសម្រេចលើផលវិបាកនៃការមិនបង្ហាញភស្តុតាងដោះបន្ទុកដូចមានចែងនៅក្នុងមាត្រា៥៤.៣.ង នៃកិច្ចព្រមព្រៀង និងការអនុវត្តន៍ដើម្បីផ្អាកការចោទប្រកាន់ជនជាប់ចោទ រួមជាមួយនឹងបញ្ហាជាក់លាក់មួយចំនួនទៀតដែលបានលើកឡើងនៅសន្និបាតស្តីពីស្ថានភាពនៃសំណុំរឿង នៅថ្ងៃទី ១០ មិថុនា ២០០៨, ICC-01/04-01/06 OA 13, ថ្ងៃទី២១ តុលា ២០០៨, មតិដាច់ដោយឡែករបស់ចៅក្រម Georghios M. Pikis, កថាខ័ណ្ឌទី ៤៤ ។

[29] បុព្វកថា នៃវិធានផ្ទៃក្នុង ។

[30] វិធាន២១.១ នៃវិធានផ្ទៃក្នុង ។

[31] វិធាន២១.១.ក នៃវិធានផ្ទៃក្នុង ។

៣. តុលាការនេះត្រូវធានាថា ជនរងគ្រោះ "មានសិទ្ធិទទួលដំណឹង" ហើយសិទ្ធិរបស់ពួកគេត្រូវបានគោរពគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី[32] ។

*ការផ្តល់ព័ត៌មានដល់សាធារណជនក្នុងពេលកិច្ចដំណើរការនីតិវិធីមុនពេលជំនុំជម្រះរបស់តុលាការនេះ*

១៩. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ជាធរមានសម្រាប់បទឧក្រិដ្ឋធម្មតានៅក្នុងតុលាការរបស់កម្ពុជា ទទួលស្គាល់ថា ការស៊ើបសួរធ្វើឡើងដោយចៅក្រមស៊ើបអង្កេត គឺជាការសម្ងាត់[33] ។ ប៉ុន្តែ ដោយសារ "ភាពជាក់លាក់ដែលជាប់មកជាមួយស្រាប់" របស់ អ.វ.ត.ក វិធាននានារបស់ខ្លួន ជាតំណាងឲ្យការចាកចេញដំណើរមួយដ៏សំខាន់ ពីគោលការណ៍ទូទៅនៃការរក្សាការសម្ងាត់នៅមុនពេលជំនុំជម្រះនេះ ។ វិធាន៥៦.១ ដែលពាក់ព័ន្ធគ្នានសល់អំពីបញ្ហានៃការផ្តល់ព័ត៌មានដល់សាធារណៈ ធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ បញ្ជាក់ថា គោលបំណងនៃការរក្សាការសម្ងាត់ក្នុងដំណាក់កាលនេះ គឺដើម្បី "ការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី"[34] ។ វិធាន៧៧.៦ ដែលពាក់ព័ន្ធគ្នានសល់អំពីបញ្ហានៃកិច្ចដំណើរការនីតិវិធីជាសាធារណៈនៅចំពោះមុខអង្គបុរេជំនុំជម្រះ នៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ បញ្ជាក់ថា សវនាការជាសាធារណៈអាចនឹងត្រូវបានធ្វើឡើង "ប្រសិនបើជាប្រយោជន៍យុត្តិធម៌ និងមិនធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ វិធានការការពាររបស់តុលាការ [នេះ]"[35] ។

*វិធាននៃភាពសម្ងាត់នៅចំពោះមុខយុត្តាធិការអន្តរជាតិ*
*ដែលអាចប្រៀបធៀបគ្នាបាន៖ ICC*

---

[32] វិធាន២១.១.គ នៃវិធានផ្ទៃក្នុង ។

[33] មាត្រា១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលចូលជាធរមាននៅថ្ងៃទី១០ សីហា ឆ្នាំ២០០៧, ច្បាប់បកប្រែជាភាសាអង់គ្លេស, បោះពុម្ពផ្សាយលើកទី១ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ។

[34] វិធាន៥៦.១ នៃវិធានផ្ទៃក្នុង ។

[35] វិធាន៧៧.៦ នៃវិធានផ្ទៃក្នុង ។

២០. លក្ខណ: និងវិសាលភាពនៃអាណត្តិរបស់ការិយាល័យអយ្យការតុលាការ ICC មានចរិកលក្ខណ:ស្រដៀងគ្នាទៅនឹងលក្ខណ: និងវិសាលភាពនៃអាណត្តិរបស់សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះនេះ ។ ឧទាហរណ៍ "ដើម្បីបង្ហាញការពិត" រដ្ឋអាជ្ញានៃតុលាការ ICC ត្រូវបានចងកាតព្វកិច្ចដោយលក្ខន្តិក:ទីក្រុងរ៉ូមសម្រាប់តុលាការ ICC - ដូចជា សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះនេះដែរ - ដើម្បី "ធ្វើការស៊ើបអង្កេតដូចៗគ្នា ទៅលើកាលៈទេសៈពិរុទ្ធកម្ម ក៏ដូចជាកាលៈទេសៈគ្មានពិរុទ្ធកម្មដែរ"[36] ។ លក្ខន្តិក:ទីក្រុងរ៉ូម ដាក់កាតព្វកិច្ចជាក់លាក់ ទៅលើរដ្ឋអាជ្ញាឱ្យធ្វើការស៊ើបអង្កេត និងប្រមូលភស្តុតាងដោះបន្ទុកក្នុងនាមជនត្រូវចោទ ហើយបន្ទាប់មកត្រូវបង្ហាញឯកសារនោះជូនទៅមេធាវីការពារក្តី បន្ទាប់ពីត្រូវបានប្រមូលរួចហើយ[37] ។ មាត្រា ៥៤.១ នៃលក្ខន្តិក:ទីក្រុងរ៉ូមបញ្ញត្តឱ្យរដ្ឋអាជ្ញាមាន "ភាពឯករាជ្យ និងភាព មិនលំអៀងក្នុងកំរិតមួយខ្ពស់" ដែលត្រូវបំពេញកិច្ចការដូចជា "មន្ត្រីយុត្តិធម៌ម្នាក់ជាជាង បំពេញកិច្ចការជាអ្នកផ្តល់ប្រឹក្សាផ្នែកច្បាប់ដែលនិយមបក្ខពួក (partisan advocate)"[38] ។ ដោយរដ្ឋអាជ្ញានៃតុលាការ ICC មានអាណត្តិនេះ និងភាពស្រដៀងគ្នាទៅនឹងការងាររបស់ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះនេះ លក្ខន្តិក:ទីក្រុងរ៉ូមមិនបានដាក់កំរិតឱ្យអនុវត្ត វិធានស្តីពីភាពសម្ងាត់ណាមួយឡើយ នៅក្នុងដំណាក់កាលស៊ើបសួរឱ្យបាន

[36] លក្ខន្តិក:ទីក្រុងរ៉ូមសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា៥៤.១.ក [*បន្ទាប់ពីនេះតទៅហៅថា* លក្ខន្តិក:ទីក្រុងរ៉ូម] ។ ដូចដែលបានចែងនៅក្នុងលក្ខន្តិក:ទីក្រុងរ៉ូម កាតព្វកិច្ចនេះគឺគ្មានពីរទេនៅក្នុងចំណោមតុលាការអន្តរជាតិ ។ បញ្ញត្តិនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងលក្ខន្តិក:ទីក្រុងរ៉ូម ជាសុខដុមកម្ម (harmonization) នៃវិធីសាស្ត្រស៊ើបសួរនៅក្នុងប្រព័ន្ធសួរដេញដោល និងប្រព័ន្ធសួរចម្លើយ (adversarial and requisitorial systems) ហើយមានចេតនានឹងធ្វើការកាត់បន្ថយនូវគម្លាតសមភាពរវាងភាគីនានា ។ ឧទាហរណ៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") នៅពេលដែលវិធាន ៦៨ នៃវិធាននីតិវិធី និងភស្តុតាងរបស់ខ្លួន បានចែងអំពីការដាក់បង្ហាញជូនដល់មេធាវីនូវសក្តានុពលនៃឯកសារដោះបន្ទុក ដែលរដ្ឋអាជ្ញាមាននៅក្នុងការកាន់កាប់របស់ខ្លួន ពេលនោះវាមិនមានករណីយកិច្ចតថានុរូប (corresponding duty) ដើម្បីធ្វើការស្រាវជ្រាវរកឯកសារបែបដូច្នោះឱ្យបានសកម្ម និងឱ្យបានចំគោលដៅទេ ។

[37] លក្ខន្តិក:ទីក្រុងរ៉ូម, មាត្រា៥៤.១.ក និង ៦៧.២ ។ សូមធ្វើការកត់សម្គាល់ពាក្យ "ត្រូវតែ, shall" នៅក្នុងមាត្រា៥៤.១ បញ្ជាក់អំពីលក្ខណ:អាណត្តិដែលមិនមែនតាមតែការសម្រេចចិត្ត (non-discretionary nature of the mandate) របស់រដ្ឋអាជ្ញាក្នុងការប្រមូលនូវភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកនោះទេ ។

[38] C.Kress, ច្បាប់នីតិវិធីសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិជាគោលសង្ខេប៖ សរីរាង្គសាស្ត្រនៃការសម្របសម្រួលដែលគ្មានពីរ, ព្រឹត្តិប័ត្រយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ច្បាប់លេខ១ ឆ្នាំ២០០៣ ទំព័រទី ៦០៣-៦១៧ ។ សូមមើលផងដែរ៖ Cassesse, ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (បោះពុម្ពផ្សាយលើកទី ២) (Oxford: OUP, 2008) ត្រង់ទំព័រទី ៤៤០ ។

ច្រើន ជាជាងអ្វីដែលបានដាក់កំរិតទៅលើភាគីនានានៃដំណើរការនីតិវិធីនៅតុលាការ ICC នៅក្នុងអំឡុងពេល ផ្សេងៗទៀតនៃដំណើរការនីតិវិធីរបស់ខ្លួនឡើយ ។ ឧទាហរណ៍ លក្ខន្តិកៈទីក្រុងរ៉ូម តម្រូវឱ្យរដ្ឋអាជ្ញា - ក្នុងអំឡុងពេលនៃការស៊ើបសួរ និងការកាត់ទោស - ចាត់វិធានការសម្រាប់ការពារជនរងគ្រោះ និងសាក្សី ព្រមទាំងការចូលរួមរបស់ពួកគេនៅក្នុងដំណើរការនីតិវិធី ។ ទោះជា យ៉ាងនេះក្តី វិធានការទាំងនេះមិនត្រូវធ្វើឱ្យខូចប្រយោជន៍ដល់ ឬមិនស្របគ្នាទៅនឹងសិទ្ធិនានា របស់ជនត្រូវចោទ និងការកាត់សេចក្តីមួយដ៏ត្រឹមត្រូវ និងមិនលំអៀងនោះឡើយ[39] ។ បទប្បញ្ញត្តិទាំងនេះបានគូសបញ្ជាក់ថា៖ ទី១) ចុងចោទត្រូវមានសិទ្ធិក្នុងការទទួលបាននូវការ កាត់សេចក្តីមួយដ៏ត្រឹមត្រូវដោយមានសមភាព និងពលសម្បទា (vigour) ពេញលេញ សូម្បីតែ ឋិតនៅក្នុងដំណាក់កាលស៊ើបសួរក៏ដោយ ។ ទី២) មិនមានកាតព្វកិច្ចនៃភាពសម្ងាត់ឯណា ធំជាងការការពារជនរងគ្រោះ និងសាក្សី ព្រមទាំងការចូលរួមរបស់ពួកគេនៅក្នុងដំណើរការនីតិវិធីនោះឡើយ ។

*ច្បាប់ស្តីពីភាពសម្ងាត់ ដូចដែលត្រូវបានពិចារណាដោយយុត្តាធិការតាមតំបន់ជឿនលឿន៖ ECHR*

២១. តុលាការសិទ្ធិមនុស្សសម្រាប់ទ្វីបអឺរ៉ុប ("ECHR") បានរំលឹកម្តងហើយម្តងទៀតថា ការណ៍ដែលសាធារណជនអាចចូលរួមបាននៅក្នុងដំណើរការនីតិវិធីតុលាការ បង្កើតបានជាគោលការណ៍មូលដ្ឋាននៃការកាត់សេចក្តីមួយដ៏ត្រឹមត្រូវ ដែលបានដាក់ដំកល់នៅក្នុងអនុសញ្ញាស្តីពីសិទ្ធិមនុស្សសម្រាប់ទ្វីបអឺរ៉ុប ("ECHR") ។ ការណ៍នេះ បានការពារគូវិវាទ "ប្រឆាំងនឹងការគ្រប់គ្រងវិស័យយុត្តិធម៌តាមបែបសម្ងាត់ដោយមិនមាន ការពិនិត្យពិច័យពីសំណាក់សាធារណជន" ។ វាក៏ជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយនានាដែលការសម្ងាត់របស់តុលាការអាចត្រូវបានថែរក្សា ។ ដោយការធ្វើឱ្យការគ្រប់គ្រងវិស័យយុត្តិធម៌មានតម្លាភាពនោះ សាធារណភាពបានធ្វើវិភាគទានទៅលើសមិទ្ធិកម្មនៃបំណងក្នុងមាត្រា ៦ កថាខណ្ឌទី ១ នៃ ECHR ជាពិសេស ការកាត់សេចក្តីមួយដ៏ត្រឹមត្រូវ គឺ "ការធានាអំពីអ្វីដែលជាគោលការណ៍មូលដ្ឋាននៃសង្គមប្រជាធិបតេយ្យ"[40] ។

---

[39] លក្ខន្តិកៈទីក្រុងរ៉ូម, មាត្រា៦៨.១ ។

[40] *ករណី Werner ទល់នឹង ប្រទេសអូទ្រីស,* សាលក្រម, ចុះថ្ងៃទី២៤ វិច្ឆិកា ១៩៩៧, ១៣៨/១៩៩៦/៧៥៧/៩៥៦, កថាខណ្ឌទី ៤៥ ។

## *ច្បាប់ និងការអនុវត្តន៍នូវភាពសម្ងាត់នៅចំពោះមុខយុត្តាធិការជាតិ៖ ប្រទេសបារាំង*

២២. មាត្រា ១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង ("ក្រមបារាំង") ចែងថា "លើកលែងតែមានបញ្ញត្តិច្បាប់ផ្ទុយពីនេះ និង *ដោយអាស្រ័យនៅលើសិទ្ធិរបស់ចុងចោទ*" ការស៊ើបសួរត្រូវតែ "*សម្ងាត់*"[41] ។ យ៉ាងនេះក្តី ភាពសម្ងាត់គឺអាស្រ័យនៅលើការកំរិត និងការលើកលែង ។ ឧទាហរណ៍ ទី១) វាអាស្រ័យលើសិទ្ធិរបស់ចុងចោទ[42] ។ ទី២) សាក្សី គឺមិនមែនភាគីណាមួយនៃដំណើរការនីតិវិធីនោះទេ អាចលាតត្រដាងនូវព័ត៌មានឱ្យទៅបណ្តាញសារព័ត៌មាន ដែលខ្លួនទទួលបានក្នុងអំឡុងពេលធ្វើការស្តាប់ចម្លើយរបស់ខ្លួនជាមួយនឹងចៅក្រម[43] ។ ទី៣) សវនាការលើការឃុំខ្លួនបណ្តោះអាសន្ន អាចត្រូវបានធ្វើឡើងជាសាធារណៈនៅចំពោះមុខ *juges des libertés et de la detention (JLD)*[44] ។ល។ នៅក្នុងសារតារច្បាប់នេះ រដ្ឋអំណាចកិត្តិយសម្នាក់ផ្នែកនីតិវិធីព្រហ្មទណ្ឌ គឺលោក Jean Pradel បានធ្វើការកត់សម្គាល់ដោយខ្លួនលោកផ្ទាល់ថា ភាពពិតប្រាកដដែលអនុវត្តលើសំណើកដ៏ទៀងទាត់នៃវិធានតឹងរឹងនានាស្តីពីភាពសម្ងាត់ ដោយសារមានការអភិវឌ្ឍន៍លើផ្នែកបច្ចេកវិជ្ជានៃការប្រាស្រ័យទាក់ទងគ្នា បណ្តាញសារព័ត៌មានសាធារណៈ និងការទទួលបានសំណុំរឿងយ៉ាងច្រើន[45] ។ អ្នកសារព័ត៌មានសរសេរ និងអ្នកជំនាញការធ្វើអត្ថាធិប្បាយអំពីដំណើរការនីតិវិធីតុលាការ ដែលកំពុងដំណើរការជាបន្តបន្ទាប់[46] ។ ជាវិធានការដ៏ធំធេង "ភាពសម្ងាត់នៃការស៊ើបសួរ [នៅប្រទេសបារាំង] គឺស្លាប់បាត់ទៅហើយ"[47] ។ លោក Pradel បានលើកឡើងថា *លើសពី*

---

[41] Jean Pradel, *កូនសៀវភៅណែនាំស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ,* បោះពុម្ពផ្សាយលើកទី ១៣, ឆ្នាំ២០០៦-២០០៧, Edition Cujas, ទំព័រទី ៤៦៣ [*បន្ទាប់ពីនេះតទៅហៅថា* Pradel] (ដែលបានលើកឡើងអំពីក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង [*បន្ទាប់ពីនេះតទៅហៅថា* ក្រមប្រទេសបារាំង]) ។ សង្កត់ន័យបន្ថែមជា *អក្សរទ្រេត* ។

[42] Pradel, ទំព័រទី ៤៦៦ ។

[43] Pradel, ទំព័រទី ៤៦៦ ។

[44] ក្រមប្រទេសបារាំង, មាត្រា ១៤៥ ។

[45] Pradel, ទំព័រទី ៤៦៦ ។

[46] Pradel, ទំព័រទី ៤៧០-១ (ដែលបានលើកឡើងអំពី *លើសពីអ្វីៗទាំងអស់ (inter alia),* ដែល "ចៅក្រមស៊ើបអង្កេតខ្លះបានអញ្ជើញអ្នកសារព័ត៌មានឱ្យមកក្នុងការិយាល័យរបស់ខ្លួន ហើយផ្តល់ជូននូវព័ត៌មានដោយផ្ទាល់") ។

[47] Pradel, ទំព័រទី ៤៧១ ។

*អ្វីៗទាំងអស់ (inter alia)* សេចក្តីសំអាងទាំងឡាយដូចតទៅនេះ យល់ស្របតាមការបើកទូលាយក្នុងការស៊ើបសួរ៖ ទី១) សេរីភាពនៃបណ្តាញសារព័ត៌មាន និងសិទ្ធិរបស់ពលរដ្ឋដែលខ្វាយខ្វល់ពីព័ត៌មាន[48] ។ ទី២) លក្ខណៈសាធារណៈនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ ពីព្រោះ " ជួនកាល ការសម្ងាត់អាចការពារបាននូវអនីត្យានុកូលភាព អយុត្តិធម៌ ឬអំពើនានាដែលមិនសមហេតុផល"[49] និងទី៣) ការចៀសវាងនូវពាក្យចចាមអារាមផ្សេងៗ[50] ។

*កត្តាពាក់ព័ន្ធសម្រាប់ធ្វើការពិចារណាដើម្បីកំណត់អំពីវិសាលភាពនៃភាពសម្ងាត់*

២៣. អង្គជំនុំជម្រះនេះ ត្រូវបានបង្កើតឡើងដើម្បីនាំយកមកនូវយុត្តិធម៌ជូនប្រជាជននៃប្រទេសកម្ពុជា ដោយសារមានការបំពានជាក់ស្តែងទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលត្រូវបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ ។ លក្ខណៈជាប្រព័ន្ធ និងជាទូទៅ នៃឧក្រិដ្ឋកម្ម ក៏ដូចជាការពន្យារពេលរហូតដល់ទៅសាមសិបឆ្នាំ ក្នុងការនាំយកមកនូវយុត្តិធម៌ជូនប្រជាជនកម្ពុជា បានធ្វើឱ្យគោលបំណងនៃអង្គជំនុំជម្រះនេះ មិនដូចគ្នាទៅនឹងគោលបំណងនៃតុលាការសាមញ្ញផ្សេងៗទៀត ។ លើសពីអ្វីៗទាំងអស់ គោលបំណងបន្ថែមនៃអង្គជំនុំជម្រះនេះមានរាប់បញ្ចូលទាំងការផ្តល់នូវឧទាហរណ៍ដល់ប្រទេសកម្ពុជាអំពីយុត្តិធម៌មួយនៃការកាត់សេចក្តីដ៏ត្រឹមត្រូវដែលត្រូវទៅតាមបមាណីអន្តរជាតិ និងជាការបន្ថែមទៅនឹងកំណត់ត្រាប្រវត្តិសាស្ត្រអំពីអ្វីដែលបានកើតឡើងក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ ។

២៤. អង្គបុរេជំនុំជម្រះ ធ្លាប់បានទទួលស្គាល់នូវលក្ខណៈពិសេស និងអាណត្តិដែលគ្មានពីររបស់អង្គជំនុំជម្រះនេះ ។ អំពីអាណត្តិនេះ អង្គបុរេជំនុំជម្រះបានរកឃើញថា អង្គជំនុំជម្រះនេះបានធ្វើខ្លួនឱ្យមានលក្ខណៈឯកទេសពិសេស និងមានវិធានផ្ទៃក្នុងរបស់ខ្លួនដែលឆ្លើយតបទៅនឹង

---

[48] Pradel, ទំព័រទី ៤៧១ (ដែលបានលើកឡើងអំពីមាត្រា ១១ ស្តីពីការប្រកាសសិទ្ធិរបស់បុគ្គល, មាត្រា១៩ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨ និងមាត្រា ១០ នៃអនុសញ្ញាទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្ស [*បន្ទាប់ពីនេះតទៅហៅថា* ECHR]) ។

[49] Pradel, ទំព័រទី ៤៧១-២ ។

[50] Pradel, ទំព័រទី ៤៧២ ។ នៅក្នុងបរិបទនេះ មានការដកស្រង់ប្រភពច្បាប់ផ្សេងៗទៀត និងតុលាការសិទ្ធិមនុស្សសម្រាប់ទ្វីបអឺរ៉ុប [*បន្ទាប់ពីនេះតទៅហៅថា* ECtHR]) ។ Pradel បានថ្លែងថា បណ្តាញសារព័ត៌មានអាចដើរតួនាទីជាអ្នកតាមឃ្លាំមើលដំណើរការនៃលទ្ធិប្រជាធិបតេយ្យ ។

"កាលៈទេសៈគ្មានពីររបស់ខ្លួន"[51] ។ ដំណើរការនីតិវិធីធម្មតារបស់កម្ពុជា នឹងយកមកអនុវត្ត នៅចំពោះមុខអង្គជំនុំជម្រះនេះ នៅពេលណាដែលមានបញ្ហាមួយកើតឡើង ហើយដែលមិនអាចដោះស្រាយបានដោយវិធាននេះ តែប៉ុណ្ណោះ[52] ។

២៥. ការបានចូលរួមដ៏សមហេតុសមផល នៅក្នុងដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះនៅគ្រប់ដំណាក់កាលទាំងអស់ ត្រូវបានគេរំពឹងថានឹងធ្វើឲ្យប្រសើរឡើងនូវកាលានុវត្តភាពដើម្បីធ្វើឲ្យសម្រេចបាននូវគោលបំណងរបស់ខ្លួន ។ ការពិនិត្យពិច័យជាសាធារណៈ គឺជាលក្ខខណ្ឌសំខាន់មួយនៃស្ថាប័នសាធារណៈទាំងអស់ ដោយរាប់ទាំងស្ថាប័នតុលាការផង ដែលជាគ្រឹះនៃការទុកចិត្តរបស់សាធារណៈជន ។ យ៉ាងនេះក៏ដោយ ភាពសម្ងាត់នៅក្នុងផ្នែកនៃដំណើរការនីតិវិធីរបស់តុលាការ គឺមានសារៈសំខាន់ដូចៗគ្នាដើម្បីការពារនូវ៖ ទី១) សិទ្ធិរបស់ចុងចោទ។ ទី២) សាក្សី និងអ្នកផ្ដល់ព័ត៌មាន ។ ទី៣) បូរណភាពនៃការស៊ើបសួរ ។ គោលដៅទាំងនេះមានសារៈសំខាន់យ៉ាងខ្លាំង ហើយតុលាការមួយ - ដូចជាអង្គជំនុំជម្រះនេះជាដើម - ត្រូវតែមានសមត្ថភាពក្នុងការបិទដំណើរការនីតិវិធីដែលបានជ្រើសរើស និងការពារនូវព័ត៌មាន ក្នុងគោលបំណងដើម្បីគោរពពួកគេ ។ យ៉ាងនេះក៏ដោយ គោលនយោបាយអំពីភាពសម្ងាត់ ត្រូវតែមានតុល្យភាពជាមួយនឹងតម្លៃដ៏ខ្ពង់ខ្ពស់ នៅក្នុងតម្លាភាពនៃស្ថាប័នសាធារណៈទូទៅ ព្រមទាំងគោលដៅ និងកាលៈទេសៈគ្មានពីរនៃអង្គជំនុំជម្រះនេះ ។

២៦. នៅក្នុងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា កាលៈទេសៈដែលធ្វើយុត្តិកម្មលើវិធាន និងនីតិវិធីដែលអនុញ្ញាតឲ្យមានការចូលរួមដ៏ទូលំទូលាយពីសំណាក់សាធារណជន នៅក្នុងដំណើរការនីតិវិធីនៃអង្គជំនុំជម្រះនេះ ព្រមទាំងឯកសារ ជារួមមានដូចតទៅនេះ ៖

ក. អង្គជំនុំជម្រះនេះ មានរចនាសម្ព័ន្ធជាកូនកាត់គ្មានពីរ ដោយមានការចូលរួមពីសំណាក់មន្ត្រីផ្លូវការជាតិ និងអន្តរជាតិ ។ ការណ៍នេះ បង្ហាញអំពីការតាំងចិត្តដែលប្រជាជន

---

[51] *ករណីរបស់ នួន ជា,* សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព, D55/I/8, ERN 00219322-00219333, កថាខណ្ឌទី ១៤ [*បន្ទាប់ពីនេះតទៅហៅថា* សាលដីកាសម្រេចលើពាក្យសុំមោឃភាព] ។

[52] សាលដីកាសម្រេចលើពាក្យសុំមោឃភាព, កថាខណ្ឌទី ១៥ ។

កម្ពុជា និងសហគមន៍អន្តរជាតិមាន ក្នុងការទទួលបានមកនូវជ័យជំនះក្នុងអាណត្តិរបស់ខ្លួន ។

ខ. កិច្ចព្រមព្រៀងបានទទួលស្គាល់នូវសេចក្តីត្រូវការសម្រាប់ដំណើរការនីតិវិធីនៃ អង្គជំនុំជម្រះនេះ ដើម្បីឱ្យសម្រេចបាននូវការកាត់សេចក្តីដ៏ត្រឹមត្រូវតាមបមាណីអន្តរជាតិ ព្រមទាំងមានការពិនិត្យពិច័យពីសំណាក់ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងបណ្តាញសារព័ត៌មាននានា[53] ។

គ. គោលដៅដ៏សំខាន់មួយនៃអង្គជំនុំជម្រះនេះ គឺការធ្វើជាគំរូដែលមានបទពិសោធន៍ល្អៗ នៅក្នុងការគ្រប់គ្រងលើវិស័យយុត្តិធម៌ និងអនុវត្តនូវការកាត់សេចក្តីដ៏ត្រឹមត្រូវសម្រាប់តុលាការកម្ពុជាផ្សេងៗទៀត ។ អង្គជំនុំជម្រះនេះ ក៏ត្រូវដើរតួសំខាន់ផងដែរ នៅក្នុងកំណែទម្រង់វិធាននៃច្បាប់នៅកម្ពុជា ។

ឃ. ការប្តេជ្ញារបស់អង្គជំនុំជម្រះនេះ ក្នុងការធ្វើការកាត់សេចក្តីដ៏ត្រឹមត្រូវតាមបមាណីអន្តរជាតិ ដែលបានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃ ICCPR ចាំបាច់ត្រូវតែបានបង្ហាញ និងត្រូវបានឃ្លាំមើលនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនិតិវិធី ដោយរាប់ទាំងដំណាក់កាលជំនុំជម្រះមុនអង្គសេចក្តីផង។ តម្រូវការបមាណីអន្តរជាតិសំខាន់ៗជាច្រើន ដូចបានរៀបរាប់ខាងលើនេះ បានចូលមកដើរតួនៅក្នុងដំណាក់កាលស៊ើបសួរនៃដំណើរការនិតិវិធី ។ ពាក់ព័ន្ធទៅនឹងវិសាលភាពដែលដំណើរការនិតិវិធីមិនធ្វើឡើងជាសាធារណៈ លទ្ធភាពនៃការសាកល្បងមើលថាតើអង្គជំនុំជម្រះនេះបានធ្វើត្រូវទៅតាមបមាណីអន្តរជាតិដែរឬទេនោះត្រូវបានកាត់បន្ថយចុះ ។ ភាពសម្ងាត់យ៉ាងតឹងរឹងនៃដំណើរការនីតិវិធី អាចត្រូវបានធ្វើការបកស្រាយថាបានដាក់ឱ្យជនត្រូវចោទឬមេធាវីការពារក្តីរបស់ខ្លួនឋិតនៅក្នុងហានិភ័យនៃការផ្តន្ទាទោសដោយសារបាននិយាយជាសាធារណៈថា មានការរំលោភទៅលើសិទ្ធិរបស់ខ្លួនក្នុងការទទួលបាននូវការ កាត់សេចក្តីមួយដ៏ត្រឹមត្រូវ ។

---

[53] កិច្ចព្រមព្រៀង, មាត្រា ១២.២ ។

ង. បទឧក្រិដ្ឋដែលជា ប្រធានបទនៃយុត្តាធិការរបស់អង្គជំនុំជម្រះនេះ បានកើតឡើងប្រមាណជាសាមសិបឆ្នាំកន្លងមកហើយ ។ អង្គជំនុំជម្រះនេះ នឹងធ្វើការចោទប្រកាន់តែទៅលើជនទាំងឡាយណាដែលត្រូវបានចោទថាជា មេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ ឬជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនៅក្រោមរបបនោះ ។ ឧក្រិដ្ឋកម្មទាំងនេះ និងអាទិចារីទាំងឡាយ (principal perpetrators) ត្រូវបានស្គាល់យ៉ាងច្បាស់ ហើយត្រូវដាក់ឱ្យឋិតនៅក្រោមការទទួលខុសត្រូវជាប្រវត្តិសាស្ត្រលើប្រជាជនស្ទើរតែទាំងមូលនៃប្រទេសនេះ ។ អង្គជំនុំជម្រះនេះ មិនមានអាណត្តិក្នុងការកាត់សេចក្តីលើឧក្រិដ្ឋកម្មទាំងឡាយដែលមានលក្ខណៈមួយជាបន្តបន្ទាប់ ឬធ្វើការដោះស្រាយចំពោះចុងចោទដែលមានចំនួនដ៏ច្រើនលើសលុបនោះទេ ។

ច. ដោយហេតុថាមានប្រជាជនកម្ពុជាភាគច្រើនលើសលុប ត្រូវបានទទួលរងគ្រោះដោយផ្ទាល់ ឬជាកូនជាចៅរបស់អ្នកដែលបានទទួលរងគ្រោះដោយផ្ទាល់ពីសំណាក់របបកម្ពុជាប្រជាធិបតេយ្យនោះ មានការចាប់អារម្មណ៍យ៉ាងខ្ពស់ជាបុគ្គល ឬជាសាធារណៈ នៅក្នុងដំណើរការនីតិវិធីនានាដែលមិនភ្ជាប់ទៅនឹងឧក្រិដ្ឋកម្មធម្មតាក្នុងស្រុកនោះឡើយ ។ ដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះនេះ មានការទាក់ទងទៅនឹងកាលៈទេសៈដែលមានការចាប់អារម្មណ៍យ៉ាងជ្រាលជ្រៅជាបុគ្គល ឬជាប្រវត្តិសាស្ត្រ ចំពោះប្រជាជនកម្ពុជា និងសាកលលោក ។

ឆ. វិធាន បានអនុញ្ញាតឱ្យជនរងគ្រោះដោយសារឧក្រិដ្ឋកម្មផ្សេងៗដែលត្រូវបានស៊ើបអង្កេត និងត្រូវបានចោទប្រកាន់ដោយអង្គជំនុំជម្រះនេះ បានចូលរួមក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដោយមានសិទ្ធិអាចចូលមើលសំណុំរឿងបាន អាចចូលរួមនៅក្នុងកិច្ចស៊ើបសួរ និងអាចស្នើសុំឱ្យមានកិច្ចស៊ើបសួរ ព្រមទាំងអាចចូលរួមនៅក្នុងបណ្តឹងឧទ្ធរណ៍នានា នៅចំពោះមុខអង្គបុរេជំនុំជម្រះទៀតផង ។ ប្រជាជនកម្ពុជារាប់លាននាក់ គឺជាជនរងគ្រោះ ឬជាសាច់ញាតិជិតដិតនឹងជនរងគ្រោះដោយសារឧក្រិដ្ឋកម្មផ្សេងៗដែលទំនងជាត្រូវបានធ្វើការកាត់សេចក្តីដោយអង្គជំនុំជម្រះនេះ ។ សិទ្ធិរបស់

ជនរងគ្រោះ ដែលក្លាយទៅជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះនេះ ត្រូវបានខូតខាតអន្តរាយ បើសិនជាពួកគេមិនបានដឹងអំពី លក្ខណៈ ទំហំ និង វិសាលភាពនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ទំហំនៃការស៊ើបសួរ ឈ្មោះរបស់ជនត្រូវចោទដែលបានជាប់ឃុំ និងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀតដែលអាចជួយដល់ពួកគេក្នុងការធ្វើសេចក្តីសន្និដ្ឋានថា ពួកគេមានព័ត៌មានពាក់ព័ន្ធផ្សេងៗដើម្បីជួយដល់អង្គជំនុំជម្រះនេះ ឬមួយក៏ដើម្បីធ្វើការទាមទារនូវសំណងផ្សេងៗ ។

ជ. បើទោះបីជាជនរងគ្រោះមិនធ្វើការជ្រើសរើសធ្វើខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែមានការពិបាកខាងផ្នែកភស្តុភារ ក្នុងការឈានទៅចាប់យកដំណាក់កាលនោះ ក៏ដោយក៏ពួកគាត់នៅតែមានការចាប់អារម្មណ៍ និងមានសិទ្ធិខាងផ្នែកសីលធម៌នៅឡើយ ក្នុងការទទួលបានមកនូវព័ត៌មាន ដែលសមស្របជាពត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ កំរិតកើនឡើងនៃពត៌មានជាសាធារណៈ គឺជាការចាំបាច់ដើម្បីធានាឲ្យបានថា ជនរងគ្រោះមួយក្រុមធំនេះបានទទួលនូវព័ត៌មានយ៉ាងគ្រប់គ្រាន់ ដើម្បីឲ្យបានយល់ ដឹងយ៉ាងពេញលេញនូវដំណើរការ និងមិនត្រូវបានរើសអើងដោយសារតែពួកគាត់ មិនបានឬមិនអាចធ្វើការជ្រើសរើសដើម្បីធ្វើខ្លួនឲ្យក្លាយទៅជាដើមបណ្តឹងរដ្ឋប្បវេណី នោះឡើយ ។

ឈ. សមត្ថភាពរបស់អង្គជំនុំជម្រះនេះ ក្នុងការបានមកនូវជំនួយសម្រាប់ជនរងគ្រោះ សាក្សី និងអ្នកប្តឹងតវ៉ានានានឹងត្រូវបានរាំងដោយសារអសមត្ថភាពរបស់បុគ្គលដែលស្ម័គ្រចិត្តនៅពេលខ្វះព័ត៌មានដ៏សមហេតុផលនានា ដែលពាក់ព័ន្ធទៅនឹងការស៊ើបសួរដែលកំពុងមានជាបន្តបន្ទាប់ ។

២៧. សិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីដ៏ត្រឹមត្រូវរបស់ចុងចោទ ដែលត្រូវបានធ្វើការវិនិច្ឆ័យពីដំបូង និងដែលត្រូវបានដោះស្រាយក្នុងអំឡុងពេលនៃដំណើរការនីតិវិធីមុនអង្គសេចក្តី អាចត្រូវបានលើកឡើងជាសាធារណៈ ដោយមិនបានធ្វើឲ្យអន្តរាយដល់បូរណភាពនៃការស៊ើបសួរដ៏ពេញលេញ ឬវិធានការការពារសម្រាប់ជនរងគ្រោះ ឬសាក្សីណាមួយឡើយ ។

ឧទាហរណ៍ ចុងចោទម្នាក់មានសិទ្ធិចូលរួមក្នុងដំណើរការនីតិវិធីសាធារណៈដើម្បីធានាថា សិទ្ធិក្នុងការបានមកនូវការកាត់សេចក្តីដ៏ត្រឹមត្រូវរបស់ខ្លួន ត្រូវបានគេការពារ ។ ផលប្រយោជន៍របស់ចុងចោទក្នុងការចូលរួមក្នុងដំណើរការនីតិវិធី ដែលត្រូវទៅតាមបមាណីអន្តរជាតិ ត្រូវបានបំរើយ៉ាងល្អបំផុតតាមរយៈការពិនិត្យពិច័យជាសាធារណៈ នៃដំណើរការនីតិវិធី លើកលែងតែផលប្រយោជន៍របស់ចុងចោទខ្លួនឯងនោះ ត្រូវបានទទួលរងនូវការប៉ះពាល់ដោយដំណើរការនីតិវិធីជាសាធារណៈ ។ យ៉ាងនេះក៏ដោយ ដំណាក់ការនៃការស៊ើបសួរ និងនៅក្នុងវិសាលភាពតូចជាងនេះនោះគឺនីតិវិធីបណ្តឹងឧទ្ធរណ៍នៅមុនអង្គសេចក្តី គឺអាចពាក់ព័ន្ធទៅនឹងដំណាក់កាលនៃការស៊ើបសួរ ដែលអាចនឹងត្រូវបានធ្វើឱ្យអន្តរាយដោយសារការដាក់បង្ហាញជាសាធារណៈ ។ ឧទាហរណ៍ ការផ្តល់សក្ខីកម្មរបស់សាក្សីអាចនឹងត្រូវបានជះ ឥទ្ធិពលដោយមិនត្រឹមត្រូវ បើសិនជាឈ្មោះ ឬសក្ខីកម្មរបស់ខ្លួនត្រូវបានដាក់បង្ហាញដោយមិនសមហេតុផល ។ ដូចគ្នានេះដែរ សហចៅក្រមស៊ើបអង្កេត មិនអាចត្រូវបានតម្រូវឱ្យដាក់បង្ហាញនូវការផ្តោតការស៊ើបសួររបស់ខ្លួនតាមរយៈការចាត់ការអនុវត្តន៍ជាសាធារណៈនៅគ្រប់ជំហាននោះបានទេ ។ ការខ្វល់ខ្វាយទាំងនេះ ត្រូវតែទទួលបាននូវការដោះស្រាយ ក៏ប៉ុន្តែអាចនឹងត្រូវបានលើកឡើងតាមរយៈការកំរិតទៅលើការចូលរួមជាសាធារណៈ នៅក្នុងដំណើរការនីតិវិធីបែបទាំងនោះ ហើយនិងនៅពេលដែលមានការអនុញ្ញាតឱ្យមានការចូលរួមដ៏សមហេតុសមផលនៅក្នុងដំណើរការនីតិវិធីផ្សេងៗទៀត ។

២៨. ការការពារអំពីអត្តសញ្ញាណរបស់ជនរងគ្រោះ និងសាក្សី គឺជាការពិចារណាមួយដ៏សំខាន់សម្រាប់តុលាការណាក៏ដោយ ហើយជាពិសេសសម្រាប់អង្គជំនុំជម្រះមួយបែបដូច្នេះ ដែលធ្វើការដោះស្រាយលើឧក្រិដ្ឋកម្មទៅលើមហាជន ដោយមានការដាក់ទោសដ៏ធ្ងន់ធ្ងរ និងដោយមានសាក្សីដែលនៅរស់រានមានជីវិតដ៏តិចតួចប៉ុណ្ណោះ ។ យ៉ាងនេះក៏ដោយ ការចាំបាច់សម្រាប់ការការពារ អាចនឹងត្រូវធ្វើឱ្យមានតុល្យភាពជាមួយនឹងតម្រូវការនៃការចូលរួមពីសំណាក់សាធារណជនដោយមានរបៀបរៀបរយ និងដោយការដាក់ទណ្ឌកម្មលើការបំពានជាការជំនួសទៅនឹងការសន្មតទុកជាមុន អំពីភាពសម្ងាត់ពាក់ព័ន្ធទៅនឹងគ្រប់សកម្មភាពទាំងអស់របស់អង្គជំនុំជម្រះ ក្នុងអំឡុងពេលនៃដំណាក់ការមុនអង្គសេចក្តី ។ បទប្បញ្ញត្តិអំពីភាពសម្ងាត់សម្រាប់ការការពារសាក្សី ត្រូវតែបានតាក់តែងឡើងដើម្បីជាការឆ្លើយតបទៅនឹង

សេចក្ដីត្រូវការ និងសំណើចាំបាច់នានា ។ ការកំរិតទៅលើលក្ខណៈជាសាធារណៈនៃដំណើរការនីតិវិធី ត្រូវតែឋិតនៅក្នុង "វិសាលភាពមួយដែលចាំបាច់ជាទីបំផុត នៅក្នុងឧត្ដមគតិរបស់តុលាការ នៅពេលមានកាលៈទេសៈពិសេសដែលសាធារណភាពនឹងធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍នៃយុត្តិធម៌"[54] ។

*សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញាលើដីកាសម្រេចអំពីភាពសម្ងាត់ដែលយោងទៅលើភាពសម្ងាត់នៃដំណើរការនីតិវិធី*

២៩. ដីកាសម្រេចអំពីភាពសម្ងាត់ ត្រូវបានចេញ *លើសពីអ្វីៗទាំងអស់ (inter alia)* ទៅតាមមាត្រា ៣.១២ នៃសេចក្ដីណែនាំអនុវត្តដែលបានចែងថា នៅពេលដែលដាក់ឯកសារ ភាគីនានាអាចបង្ហាញពីសំណូមពររបស់ខ្លួនដើម្បីដាក់ឯកសារនោះ (ជាអត្ថបទ "សាធារណៈ" "សម្ងាត់" ឬ "បិទស្លាកបោះត្រា") គឺមានតែ អង្គភាពតុលាការពាក់ព័ន្ធតែប៉ុណ្ណោះ ដែលធ្វើការកំណត់ទៅលើប្រភេទឯកសារនោះ[55] ។ ជាការរំលឹកឡើងវិញអំពីបញ្ញត្តិនោះ ដីកាសម្រេចអំពីភាពសម្ងាត់ បានរកឃើញថា ក្រុមមេធាវីការពារក្ដីបានដាក់ "ឯកសារសំណុំរឿងចំនួនប្រាំបួនទៅក្នុង [វិបសាយរបស់ក្រុមមេធាវីការពារក្ដី] ដែលឯកសារទាំងនោះមិនដែលត្រូវបានអនុញ្ញាតដោយចៅក្រមទេ"[56] ។ ឯកសារទាំងប្រាំបួនដែលមានលក្ខណៈ "ប្រមាថ"[57] នេះ មិនត្រូវបានកំណត់អត្តសញ្ញាណថាជាឯកសារអ្វីនោះទេ នៅក្នុងដីកាសម្រេចអំពីភាពសម្ងាត់[58] ។ ដីកាសម្រេចអំពីភាពសម្ងាត់ ក៏បានបង្គាប់ឱ្យក្រុមមេធាវីការពារក្ដីបញ្ឈប់ការដាក់ព័ត៌មានដែលពាក់ព័ន្ធទៅនឹងការស៊ើបសួរ បញ្ចូលទៅក្នុង វិបសាយរបស់ក្រុមមេធាវីការពារក្ដី "ក្រៅតែពីឯកសារទាំងឡាយដែលចុះផ្សាយនៅលើវិបសាយរបស់ អ.វ.ត.ក"[59] ។

---

[54] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤ ។

[55] ដីកាសម្រេចអំពីភាពសម្ងាត់, ទំព័រទី ១ ។

[56] ដីកាសម្រេចអំពីភាពសម្ងាត់, កថាខណ្ឌទី ៥ ។

[57] ដីកាសម្រេចអំពីភាពសម្ងាត់, ទំព័រទី ៧ ។

[58] ដីកាសម្រេចអំពីភាពសម្ងាត់, កថាខណ្ឌទី ៥ ។

[59] ដីកាសម្រេចអំពីភាពសម្ងាត់, ទំព័រទី ៧ ។

៣០. សហព្រះរាជអាជ្ញា ស្នើឲ្យអង្គបុរេជំនុំជម្រះ ធ្វើការពិចារណាទៅលើភាពសមហេតុសមផល នៃដីកាសម្រេចអំពីភាពសម្ងាត់នេះ ដោយលើសពីអ្វីៗទាំងអស់ អាស្រ័យលើកត្តា ទាំងឡាយ ដូចតទៅនេះ ៖

ក. តើវិធាន បានបង្កើតកាតព្វកិច្ចវិជ្ជមាន ឲ្យដល់អង្គភាពតុលាការនៃអង្គជំនុំជម្រះនេះ - ដោយរាប់បញ្ចូលទាំងក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរផង - ក្នុងការបន្តផ្តល់ជូននូវព័ត៌មានអំពីដំណើរការនីតិវិធីនៃអង្គជំនុំជម្រះនេះ ឲ្យដល់ជនរងគ្រោះដែរឬទេ? វិធាន ២១.១.ក បានចែងអំពី "គោលការណ៍ជាសារវ័ន្ត" នៃអង្គជំនុំជម្រះនេះ ថា នឹងធ្វើការធានាដល់ "ជនរងគ្រោះ (ហើយគឺមិនមែនត្រឹមតែដើមបណ្តឹងរដ្ឋប្បវេណីដែលបានចុះបញ្ជីរួចហើយនោះទេ) ត្រូវបន្តផ្តល់ជូននូវព័ត៌មាន ហើយសិទ្ធិរបស់ពួកគេត្រូវបានគោរពក្នុងអំឡុងពេលនៃដំណើរការនីតិវិធី" ។

ខ. តើនៅក្នុងអង្គជំនុំជម្រះ មានគោលការណ៍ណែនាំណាខ្លះដែលធ្វើការកំណត់ថាតើឯកសារណាមួយនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ - និងនៅក្នុងរយៈពេលណា - ដែលត្រូវបានចាត់ទុកថាជា សម្ងាត់ ហើយអ្វីផ្សេងទៀតជា សាធារណៈ?

គ. តើការអនុវត្តន៍របស់អង្គបុរេជំនុំជម្រះ ក្នុងការចេញសេចក្តីសម្រេចដោយមានសំអាងដែលធ្វើការកំណត់ទៅលើប្រភេទឯកសាររបស់ភាគីមួយដែលដាក់ជាសាធារណៈ ថាជាអត្ថបទ"សម្ងាត់" ដែលត្រូវបានអនុម័តដោយសារគ្រប់ឯកសារទាំងនោះ ត្រូវបានធ្វើការកំណត់ប្រភេទសារជាថ្មីពី "សាធារណៈ" ទៅជា "សម្ងាត់"?[60]

ឃ. តើសេចក្តីសម្រេចដោយមានសំអាងដើម្បីធ្វើការកំណត់ប្រភេទសារជាថ្មី មានសារៈសំខាន់សម្រាប់ភាគីមួយក្នុងការស្វែងរកនូវដំណោះស្រាយលើបណ្តឹងឧទ្ធរណ៍ ឬលើនីតិវិធីផ្សេងទៀតដែរឬទេ? តើសេចក្តីសម្រេចនេះ ត្រូវធ្វើការកំណត់អត្តសញ្ញាណលើ

---

[60] *ករណីរបស់ អៀង សារី,* សេចក្តីសម្រេចដោយអនុលោមតាមមាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ៖ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ចំពោះការតែងតាំងអ្នកជំនាញ, A189/I/6, ERN 00207784-00207785, កថាខណ្ឌទី ៤ ។

"*ព័ត៌មានសម្ងាត់*" ដោយសារតែ *ព័ត៌មាន* នេះទើបឯកសារនោះត្រូវបានកំណត់ប្រភេទថាជា "សម្ងាត់" ដែរឬទេ?[61]

ង. តើការដាក់[ឯកសារ]នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គួរត្រូវបានជូនដំណឹងដល់ភាគីនានា ដោយមានការបញ្ជូនដ៏សមហេតុសមផល ដើម្បីឱ្យភាគីនានាស្វែងរកនូវដំណោះស្រាយប្រឆាំងនឹងការកំណត់ប្រភេទ[ឯកសារ]របស់ពួកគាត់ ដែរឬទេ?

ច. តើដីកាសម្រេចអំពីភាពសម្ងាត់បានបកស្រាយយ៉ាងត្រឹមត្រូវនូវវាក្យស័ព្ទ ដែលកំណត់ព្រំដែនថា "សាធារណៈ" នៅក្នុងមាត្រា ៣.១២ នៃសេចក្ដីណែនាំអនុវត្តនោះមានន័យថា"ឯកសារដែលបានចុះផ្សាយនៅលើវិបសាយរបស់ អ.វ.ត.ក" ដែរឬទេ?[62] ។

ឆ. តើដីកាសម្រេចអំពីភាពសម្ងាត់បានពន្លាតទំហំ និងវិសាលភាពនៃភាពសម្ងាត់តាមវិធាន ៥៦.១ ដោយការបន្ថែមការពិចារណា ដូចជាលក្ខខណ្ឌតម្រូវនៃ "judicial calendar" ដែរឬទេ?[63] ។ វិធាន ៥៦.១ ចែងអំពីការរក្សាការសម្ងាត់ដើម្បីការពារ "សិទ្ធិ និងផលប្រយោជន៍របស់ភាគី" តែប៉ុណ្ណោះ[64] ។

ជ. តើការបំពានលើភាពសម្ងាត់ នៃឯកសារមួយដែលបានដាក់នៅចំពោះមុខអង្គភាពតុលាការជាក់លាក់ណាមួយនៃអង្គជំនុំជម្រះនេះ ជាបញ្ហានៃការដាក់វិន័យតាមផ្លូវតុលាការ គួរត្រូវបានដោះស្រាយដោយអង្គភាពជាក់លាក់នោះតែម្នាក់ឯង ដែរឬទេ?

ឈ. តើឯកសារដែលមានជាប់ទាក់ទងនឹងសុខភាពរបស់ចុងចោទណាម្នាក់ ហើយនិងឯកសារបែបដូច្នេះផ្សេងៗទៀត ដែលចាំបាច់សម្រាប់ការការពារសិទ្ធិរបស់ខ្លួនក្នុងការ

[61] វិធាន ៣៥.១.ក, ការដាក់ទណ្ឌកម្មទៅលើការផ្សាយចេញនូវ "ព័ត៌មាន" សម្ងាត់ (ដែលជាការផ្ទុយទៅនឹង "ឯកសារ" សម្ងាត់) ។

[62] ដីកាសម្រេចអំពីភាពសម្ងាត់, ទំព័រទី ៧ (មានបញ្ញត្តនៅក្នុង កថាខណ្ឌទី ១.ក ) ។

[63] ដីកាសម្រេចអំពីភាពសម្ងាត់, កថាខណ្ឌទី ១២ ។

[64] វិធាន ៥៦.១ នៃវិធានផ្ទៃក្នុង ។

ទទួលបាននូវការកាត់សេចក្តីដ៏ត្រឹមត្រូវ គួរត្រូវបានពិចារណាដោយសន្មតថាជាសាធារណ: ដែរឬទេ?[65]

ញ. តើឯកសារដែលរកបានតាមមធ្យោបាយជាសាធារណៈឬបានមកជាឯកជន ដែលបានដាក់ជូនជាឯកសារភ្ជាប់នៅចំពោះមុខអង្គជំនុំជម្រះនេះក៏ជាឯកសារ"សម្ងាត់" ផងដែរឬទេ?[66]

ដ. តើវិធាន ២៩ - ដែលទាក់ទងនឹងវិធានការការពារ - ហើយនិងសេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារមិនបានផ្តល់អំណាច និងយន្តការគ្រប់គ្រាន់ឲ្យដល់អង្គជំនុំជម្រះនេះដើម្បីធានាការពារដល់ជនរងគ្រោះ និងសាក្សី នៅពេលបំពេញកាតព្វកិច្ចរបស់ខ្លួនដើម្បីបន្ត"ផ្តល់ព័ត៌មានដល់ជនរងគ្រោះ" - ទៅតាមវិធាន ២១.១.ក - នៅក្នុងរយៈពេលនៃកិច្ចដំណើរការនីតិវិធី ដែរឬទេ?[67]

៣១. ដោយមានជាប់មកជាមួយនូវសិទ្ធិជាមូលដ្ឋានក្នុងការបានមកនូវការជំនុំជម្រះក្តី និងសេចក្តីវិនិច្ឆ័យមួយដោយមានសំអាងត្រឹមត្រូវ ស្របទៅតាមការជំនុំជម្រះក្តីនោះ នៅក្នុងដំណើរការនីតិវិធីជាសាធារណ: តើជាសិទ្ធិរបស់ភាគីមួយក្នុងការដាក់បង្ហាញជាសាធារណៈនូវសារណារបស់ខ្លួននៅចំពោះមុខអាជ្ញាធរតុលាការដែរឬទេ?បញ្ហានេះបានអនុញ្ញាតឲ្យអ្នកសង្កេតការណ៍ឯករាជ្យ ធ្វើការវាយតម្លៃលើសេចក្តីសំអាងនានារបស់ភាគីផ្សេងៗ ដែលអង្គភាពតុលាការយកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តីរបស់ខ្លួន ។ ការណ៍នេះ បានអនុញ្ញាតឲ្យមានការវិភាគមួយអំពីអ្វីដែលការពិចារណាបានយកមកធ្វើការថ្លឹងថ្លែង ដើម្បីឲ្យអង្គភាពតុលាការធ្វើសេចក្តីសម្រេចចិត្ត ហើយនិងថាតើការពិចារណាទាំងនោះមានការពាក់ព័ន្ធគ្នាដែរឬទេ ។

---

[65] ដីកាសម្រេចអំពីភាពសម្ងាត់, កថាខណ្ឌទី ១៦-១៧ ។ របាយការណ៍របស់វេជ្ជបណ្ឌិត Falke បានពោលនៅក្នុងកថាខណ្ឌទី ១៦ នៃដីកាសម្រេចអំពីភាពសម្ងាត់ គឺជារបាយការណ៍ឯកជនមួយដែលលោកវេជ្ជបណ្ឌិតម្នាក់បានផ្តល់ឲ្យក្រុមមេធាវីការពារក្តី ដែលពេលក្រោយមក ត្រូវបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ។ បណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តីដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី ១៨ មានជាប់ទាក់ទងទៅនឹងស្ថានភាពសុខភាពរបស់ដើមបណ្តឹងឧទ្ធរណ៍ ។

[66] ដីកាសម្រេចអំពីភាពសម្ងាត់, កថាខណ្ឌទី ១៦ ។

[67] សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ, អ.វ.ត.ក/០៣/២០០៧/ច្បាប់វិសោធនកម្មលើកទី១, ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨ ។

វាបានអនុញ្ញាតឱ្យមានការវាយតម្លៃមួយអំពីភាពត្រឹមត្រូវនៃដំណើរការនីតិវិធី នៅចំពោះមុខអាជ្ញាធរតុលាការ ។ អង្គបុរេជំនុំជម្រះ ធ្លាប់បានធ្វើតាមសេចក្តីណែនាំនេះជាទៀងទាត់ តាមរយៈការដាក់បង្ហាញជូនជាសាធារណៈ មិនត្រឹមតែសេចក្តីសម្រេចនានារបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឯកសារផ្សេងៗដែលភាគីនានាបានដាក់ ដែលជាមូលដ្ឋាននៃការសម្រេចសេចក្តីទាំងនេះថែមទៀតផង ។

៣២. ដោយបានធ្វើនូវសេចក្តីសង្កេតទាំងនេះ សហព្រះរាជអាជ្ញា បានធ្វើការកត់សម្គាល់ថា វាក៏ជាករណីយកិច្ចមួយរបស់ក្រុមមេធាវីការពារក្តី ក្នុងការបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះនេះ ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គភាពនានានៃអង្គជំនុំជម្រះ ហើយនិងធ្វើការស្វែងរកនូវសេចក្តីសម្រេចផ្សេងៗដែលពាក់ព័ន្ធទៅនឹងសារទុក្ខផ្សេងៗ ដែលពួកគេអាចនឹងមាន ។ ការណ៍នេះ រាប់បញ្ចូលទាំងសាទុក្ខផ្សេងៗដែលពាក់ព័ន្ធទៅនឹងការកំណត់ប្រភេទឯកសារថា "សម្ងាត់" ។ ក្នុងនាមនេះ សហព្រះរាជអាជ្ញា បានធ្វើការកត់សម្គាល់ថា ដើមបណ្តឹងឧទ្ធរណ៍ មិនបានធ្វើការស្វែងរកនូវការយល់ព្រមណាមួយពីសំណាក់អង្គបុរេជំនុំជម្រះ ដើម្បីដាក់បញ្ចូលបណ្តឹងឧទ្ធរណ៍របស់ខ្លួនស្តីពីការចាត់តាំងអ្នកជំនាញចិត្តសាស្ត្រ ទៅក្នុងវិបសាយរបស់ក្រុមមេធាវីការពារក្តី ។ ថ្វីបើមានការទទូចទាមទាររបស់ភាគីប្តឹងឧទ្ធរណ៍ ហើយតថភាពដែលថាឯកសារនោះមិនមានផ្ទុកនូវឯកសារដែលត្រូវបានការពារ លើកលែងតែឯកសារយោងអំពីកំណត់ត្រាសុខភាពរបស់ដើមបណ្តឹងឧទ្ធរណ៍ ដែលខ្លួនអាចនឹងធ្វើការបោះបង់ចោលបាន ដែលជាដំណើររឿងមួយដ៏ត្រឹមត្រូវសម្រាប់ដើមបណ្តឹងឧទ្ធរណ៍នោះគឺ គួរតែធ្វើការស្វែងរកការអនុញ្ញាតពីសំណាក់អង្គបុរេជំនុំជម្រះដើម្បីធ្វើវាឱ្យទៅជាសាធារណៈ តាមរយៈការធ្វើការកំណត់ប្រភេទឯកសារនេះឡើងវិញ ដោយដាក់ឯកសារនោះថាជា "សាធារណៈ" ។ បើទៅតាមសេចក្តីសម្រេចមួយដែលមានសំអាង បញ្ហានេះគឺមកពីអង្គបុរេជំនុំជម្រះបានចាត់ទុកឯកសារនេះ ថាជាឯកសារដែលបានដាក់ជា "សម្ងាត់" ។

## ខ. វិសាលភាព ចរិតលក្ខណៈ និង នីតិវិធីនៃការផ្តន្ទាទោស ចំពោះការបំពារបំពានលើភាពសម្ងាត់

### *ច្បាប់ជាធរមានស្តីពីការរំលោភបំពានលើភាពសម្ងាត់*

**ក. ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់ អ.វ.ត.ក**

៣៣. វិធាន៣៥ ទាក់ទងទៅនឹងការដាក់ទណ្ឌកម្មទៅលើជនទាំងឡាយ-រួមទាំងមេធាវីការពារក្ដីផង-ដែល ["ជ្រៀតជ្រែក"] ចូលក្នុងកិច្ចការរដ្ឋបាលរបស់ អ.វ.ត.ក"[68] ។ វិធាននេះ អនុញ្ញាតឲ្យធ្វើការដាក់ទណ្ឌកម្ម ឬ "បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច" នូវជនណាម្នាក់ដែលជ្រៀតជ្រែកដោយ "បានដឹង និងមានចេតនាពិតប្រាកដ" ចូលក្នុងកិច្ចការរដ្ឋបាលរបស់ អ.វ.ត.ក ដោយផ្សាយចេញ "ព័ត៌មានសម្ងាត់" ដោយរំលោភទៅលើដីកាណាមួយ ។ ហេតុដូចនេះចំពោះការដាក់ទណ្ឌកម្ម ដូចចែងក្នុងបញ្ញត្តិនេះ គឺដើម្បីជំរុញអនុវត្តចំពោះ (១) ជនណាដែលបានចូលជ្រៀតជ្រែកនៅក្នុងកិច្ចការរដ្ឋបាលរបស់អ.វ.ត.ក។ (២) ការចូលជ្រៀតជ្រែកនោះត្រូវតែបានធ្វើឡើងដោយបានដឹងនិងដោយមានចេតនាពិតប្រាកដ ។ (៣) ជននោះត្រូវតែបានផ្សាយចេញ "ពត៍មាន" សម្ងាត់ និង ការផ្សាយចេញនេះ ត្រូវតែជាការរំលោភទៅលើ "ដីកា" ណាមួយ ។

៣៤. ការដាក់ទណ្ឌកម្មដើម្បីផ្ដន្ទាទោសណាមួយតាមវិធាន៣៥ អាចនឹងត្រូវបានផ្ដួចផ្ដើមគំនិតក្រោយពីអាជ្ញាធរមានសមត្ថកិច្ចណាមួយដែលពាក់ព័ន្ធរបស់តុលាការ មានហេតុផលជឿថា បុគ្គលណាម្នាក់ធ្លាប់បានប្រព្រឹត្តអំពើណាមួយដែលបណ្ដាលឲ្យមានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ។ ក្រោយពីជឿដូចនេះ អាជ្ញាធរមានសមត្ថកិច្ចរបស់តុលាការអាច (១) ចាត់ការជាមួយបញ្ហានេះជាបន្ទាន់។ (២) ដឹកនាំការស៊ើបសួរបន្ថែម។ ឬ (៣) បញ្ជូនរឿងនេះ ឲ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ឬអង្គការសហប្រជាជាតិ[69] ។

៣៥. ជនទាំងឡាយណាដែលពាក់ព័ន្ធក្នុងដំណើរការនីតិវិធីដូចមានចែងក្នុងវិធាន៣៥ "ត្រូវ" មានសិទ្ធិ បានទទួលបាននូវជំនួយផ្នែកច្បាប់[70] ។ ច្បាប់កម្ពុជាជាធរមានត្រូវអនុវត្ត "ចំពោះករណីទណ្ឌកម្មនីមួយៗ"លើបុគ្គលណាម្នាក់ដែលត្រូវបានរកឃើញថារំលោភបំពានលើវិធាន៣៥[71]។

---

[68] វិធាន៣៥.១ នៃវិធានផ្ទៃក្នុង ។

[69] វិធាន៣៥.២ នៃវិធានផ្ទៃក្នុង ។

[70] វិធាន៣៥.៣ នៃវិធានផ្ទៃក្នុង ។

[71] វិធាន៣៥.៥ នៃវិធានផ្ទៃក្នុង ។

## ខ. កំហុសវិជ្ជាជីវៈរបស់មេធាវី

៣៦. ប្រសិនបើរកឃើញថាមេធាវីណាម្នាក់ រំលោភបំពានលើវិធាន៣៥ ដោយចូលជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អ.វ.ត.ក ដូចជាករណីដែលនៅក្នុងបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះ - អាជ្ញាធរ មានសមត្ថកិច្ចដែលពាក់ព័ន្ធរបស់តុលាការក៏អាចកំណត់ដែរថា ការជ្រៀតជ្រែកបែបនេះ គឺបានឈានទៅដល់កំហុសវិជ្ជាជីវៈរបស់មេធាវី អនុលោមតាមវិធាន៣៨នៃវិធានផ្ទៃក្នុង[72] ។

៣៧. តាមវិធាន៣៨ នៃវិធានផ្ទៃក្នុង អង្គភាពណាមួយរបស់តុលាការនេះអាចដាក់ទណ្ឌកម្មប្រឆាំងនឹងមេធាវីណាម្នាក់ដែលកំពុងតែបង្ហាញខ្លួននៅចំពោះមុខតុលាការ ប្រសិនបើរកឃើញថា ការប្រព្រឹត្តរបស់មេធាវីរូបនោះ (១) ជាការប្រមាថមើលងាយឬរំលោភបំពាន។ (២) រាំងស្ទះដល់ដំណើរការនីតិវិធី។(៣)រំលោភទៅលើរឿងក្តី។ ឬ (៤) ម្យ៉ាងទៀតផ្ទុយនឹងមាត្រា២១.៣ នៃកិច្ចព្រមព្រៀង[73] ។ មាត្រា២១.៣ ចែងថាតួនាទីភារកិច្ចរបស់មេធាវីណាម្នាក់ដែលត្រូវបានចាត់តាំងឬជួល ដែលបង្ហាញខ្លួននៅចំពោះមុខតុលាការនេះ "ត្រូវ"អនុវត្តតាមកិច្ចព្រមព្រៀងនេះ ច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈមេធាវី បទដ្ឋាន និងសីលធម៌នៃវិជ្ជាជីវៈខាងផ្នែកច្បាប់ដែលគេទទួលស្គាល់[74] ។

៣៨. ការរកឃើញណាមួយ អំពីកំហុសវិជ្ជាជីវៈអាចធ្វើទៅបានតែ "នៅក្រោយពេលធ្វើការព្រមានរួចហើយ" តែប៉ុណ្ណោះ[75] ។

### *វិធាននៃការដាក់ទណ្ឌកម្មនៅចំពោះមុខយុត្តាធិការអន្តរជាតិនានា ដែលស្រដៀងគ្នានេះ*

៣៩. តុលាការអន្តរជាតិនានាទាំងអស់ក្នុងពេលបច្ចុប្បន្ន ដែលធ្វើការកាត់សេចក្តីអំពីឧក្រិដ្ឋកម្មនានាដែលស្រដៀងគ្នានឹងតុលាការនេះ និងដែលប្រើប្រាស់សេវាមេធាវីការពារក្តីដែលមានចម្រុះ

[72] វិធាន៣៥.២ នៃវិធានផ្ទៃក្នុង ។

[73] វិធាន៣៨.១ នៃវិធានផ្ទៃក្នុង ។

[74] កិច្ចព្រមព្រៀង, មាត្រា២១.៣ ។

[75] វិធាន៣៨.១ នៃវិធានផ្ទៃក្នុង ។

ជាតិនិងដែលមកពីយុត្តាធិការដែលមានប្រវត្តិដើមចម្រុះគ្នា សុទ្ធតែបានអនុម័តនូវបទបញ្ញត្តិសម្រាប់ដោះស្រាយចំពោះការជ្រៀតជ្រែកនៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ឬចំពោះកំហុសវិជ្ជាជីវៈដោយមេធាវីការពារក្តី ។ ឧទាហរណ៍ដូចជា លក្ខន្តិកៈនៃទីក្រុងរ៉ូមរបស់តុលាការ ICC បានបង្កើតឡើងនូវ "*បទល្មើសផ្សេងៗ* ដែលប្រឆាំងនិងកិច្ចការរដ្ឋបាលរបស់តុលាការ" និងបានចែងកំណត់ពីការផ្តន្ទាទោសចំពោះបទល្មើសទាំងនោះទៀតផង[76] ។ លក្ខន្តិកៈនោះក៏បានចែងកំណត់ពីទោសបញ្ញត្តិសម្រាប់ផ្តន្ទាទោសចំពោះ "កំហុសវិជ្ជាជីវៈ" ដែលរួមមានការប្រកែកមិនព្រមអនុវត្តតាមសេចក្តីណែនាំរបស់តុលាការផងដែរ[77] ។ ចំពោះបទល្មើសផ្សេងៗដែលប្រឆាំងនឹងកិច្ចការរដ្ឋបាលរបស់តុលាការ នៅក្នុងវិធានស្តីពីនីតិវិធីនិងភស្តុតាងរបស់តុលាការ ICC ("វិធាននៃ ICC") មានចែងយ៉ាងលំអិតអំពីយន្តការមួយក្នុងការពិគ្រោះពិភាក្សាយោបល់គ្នា ក្នុងការស៊ើបអង្កេត ការចាប់ខ្លួន ការចោទប្រកាន់ និងក្នុងការជំនុំជម្រះ ក្តីលើករណីរបស់ជនទាំងឡាយណា ដែលត្រូវបានចោទប្រកាន់អំពី "បទល្មើសផ្សេងៗដែលប្រឆាំងនឹងកិច្ចការរដ្ឋបាល" នៅមុនពេលដែលការដាក់ទណ្ឌកម្មត្រូវបានធ្វើឡើងចំពោះបទល្មើសទាំងនោះ[78] ។ ដំណើរការនីតិវិធីទាំងនេះ ជាការច្បាស់លាស់ណាស់ថា សុទ្ធតែមានលក្ខណៈជាបទព្រហ្មទណ្ឌ ។ ចំពោះកំហុសខាងវិជ្ជាជីវៈ ក្នុងទម្រង់ជាការ បដិសេធមិនព្រមអនុវត្តតាមសេចក្តីនែនាំរបស់តុលាការនោះនៅក្នុងវិធាននៃ ICC បានចែងថាការដាក់ទណ្ឌកម្មនៅក្រោយពេលបានធ្វើការ "ព្រមានថានឹងដាក់ទណ្ឌកម្មក្នុងករណីមានកំហុសវិជ្ជាជីវៈ" និងក្រោយពីបាន "ផ្តល់ឱកាសឲ្យផ្តល់ចម្លើយ បំភ្លឺនៅមុនពេលធ្វើការដាក់ទណ្ឌកម្មណាមួយ"[79] ។

៤០. ដំណើរការនិតិវិធីដែលស្រដៀងគ្នានេះ - ដែលមានលក្ខណៈជាបទព្រហ្មទណ្ឌ - ក៏បានចែងផងដែរ ក្រោមការប្រមាថមើលងាយ ចំពោះយុត្តាធិការនានានៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") និងសម្រាប់ប្រទេសរ្វ៉ាន់ដា ("ICTR") និង

---

[76] លក្ខន្តិកៈនៃទីក្រុងរ៉ូម មាត្រា៧០ ។ សង្កត់ធ្ងន់ត្រង់អក្សរទ្រេត ។

[77] លក្ខន្តិកៈនៃទីក្រុងរ៉ូម មាត្រា៧១ ។

[78] វិធាន១៦២-៩ នៃវិធានរបស់តុលាការ ICC ស្តីពីនីតិវិធី និងភស្តុតាង ។

[79] វិធាន១៧១ នៃវិធានរបស់តុលាការ ICC ស្តីពីនីតិវិធី និងភស្តុតាង ។

តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន (“SCSL”)[80] ។ តុលាការទាំងនោះបានរកឃើញថាតុលាការរបស់ពួកគេបានមានយុត្តាធិការមួយ ដែលជាប់មកជាមួយស្រាប់ពីធម្មជាតិមក ដែលកើតមកពីមុខងាររបស់ពួកគេជាតុលាការ សម្រាប់ធានាឲ្យប្រាកដថា ការអនុវត្តន៍នូវយុត្តាធិការរបស់ពួកគេនឹងមិនត្រូវបរាជ័យនោះទេ ហើយថា មុខងារជាមូលដ្ឋានខាងតុលាការរបស់ពួកគេគឺត្រូវបានថែរក្សាការពារ[81] ។ ក៏ប៉ុន្តែតុលាការ ICTY បានឲ្យប្រុងប្រយ័ត្នថា ច្បាប់ស្តីពីការប្រមាថមើលងាយតុលាការ គឺមិនមែនបង្កើតឡើងសម្រាប់ “ជាជន្ទល់សម្រាប់ជួយទល់ទ្រ ការពារដល់សេចក្តីថ្លៃថ្នូររបស់ចៅក្រមទាំងឡាយឲ្យបានមាំ ឬដើម្បីគ្រាន់តែដាក់ទណ្ឌកម្មចំពោះការមើលងាយ ឬការជេរប្រមាថចំពោះតុលាការឬសាលាក្តីនោះទេ”[82] ។ អាស្រ័យហេតុនេះ តុលាការទាំងនោះមិនបានចាត់ចូលជាបទព្រហ្មទណ្ឌនូវគ្រប់រាល់ទម្រង់នៃបទល្មើសទាំងអស់ទោរាប់បញ្ចូលទាំងការផ្សាយចេញនូវពត៌មានសម្ងាត់ផង ។ នៅក្នុងករណីរឿងក្តីរបស់ *Ntakirikumana* តុលាការ ICTY បានរកឃើញថា ការផ្សាយចេញដោយរំលោភទៅលើដីកាសម្រេចស្តីពីការការពារសាក្សី គឺមិនទាន់មានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ ដូចគ្នានឹងអំពើប្រមាថមើលងាយតុកាការនោះទេ[83] ។ នៅក្នុងករណីរឿងក្តីរបស់ *Furundzija* តុលាការICTY ប្រកាន់យកការយល់ឃើញថា គំរូនៃការរំលោភទៅលើដីកានានារបស់ខ្លួនដោយខាងអយ្យការគឺមិនមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ដែលឈានទៅដល់កម្រិតជាបទល្មើសព្រហ្មទណ្ឌ ស្តីពីបទប្រមាថមើលងាយនោះទេ ដោយសារមានតែជាការជ្រៀតជ្រែកទាំងឡាយដ៏ធ្ងន់ធ្ងរ បំផុតចូលក្នុងកិច្ចការរដ្ឋបាលតែប៉ុណ្ណោះ ដែលមានបំណងចង់ឲ្យធ្វើការចោទប្រកាន់

---

[80] វិធាន៧៧ នៃវិធានរបស់តុលាការ ICTY ស្តីពីនីតិវិធី និងភស្តុតាង ។ វិធាន៧៧ នៃវិធានរបស់តុលាការ ICTR ស្តីពីនីតិវិធី និងភស្តុតាង។ វិធាន៧៧ នៃវិធានរបស់តុលាការ SCSL ស្តីពីនីតិវិធី និងភស្តុតាង ។

[81] សេចក្តីសម្រេចស្តីពីការប្រមាថរបស់ Tadic, ត្រង់កថាខណ្ឌទី១៣ (ដែលលើកសំអាងទៅលើយុត្តិសាស្ត្ររបស់តុលាការយុត្តធម៌អន្តរជាតិ (“ICJ”) និងរបស់តុលាការ ICTY) ។

[82] សេចក្តីសម្រេចស្តីពីការប្រមាថរបស់ Tadic, កថាខណ្ឌទី១៦ ។

[83] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Ntakirutimana,* សេចក្តីសម្រេចលើញត្តិស្នើសុំរបស់អយ្យការស្តីពីការប្រមាថតុលាការ និងលើញត្តិស្នើសុំរបស់មេធាវីចំនួនពីររូប ឲ្យធ្វើការបង្ហាញជូន ចុះថ្ងៃទី ១៦ កក្កដា ២០០១ របស់អង្គជំនុំជម្រះសាលាដំបូង នៃ តុលាការ ICTR , កថាខណ្ឌទី១០-១២ ។

នៅក្រោម ចំណងជើងនេះ[84] ។ នៅក្នុងករណីរឿងក្តីរបស់ *Bradjanin* តុលាការ ICTY បានរកឃើញថា មានបទចោទមួយស្តីពីការប្រមាថមើលងាយ ដែលមិនបានបំពេញទៅតាមកម្រិតដែលបានតម្រូវនោះទេ ដោយសារតែព័ត៌មានដែលត្រូវបាននិយាយថា ត្រូវបានផ្សាយចេញដោយ រំលោភទៅលើដីការបស់តុលាការនោះ ត្រូវបានគេដាក់ជាកម្មសិទ្ធសាធារណៈរួចហើយ[85] ។

៤១. ការរំលោភលើដីការបស់តុលាការ បែបនេះ គឺបង្កើតបានជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ[86] ។ ដីការបស់តុលាការនៅតែស្ថិតនៅជាធរមានដដែលរហូតទាល់តែអង្គជំនុំជម្រះសម្រេចផ្សេងពីនេះ[87] ។ *អំពើពិរុទ្ធ* នៃបទល្មើសពីបទរំលោភលើដីការបស់តុលាការណាមួយ គឺជាអំពើជារូបវន្តនៃការផ្សាយចេញនូវព័ត៌មានដែលទាក់ទងទៅនឹងដំណើរការនៃនីតិវិធីដែលល្មើសទៅនឹងដីការបស់អង្គជំនុំជម្រះ[88] ។ ការផ្សាយចេញនូវព័ត៌មានសម្ងាត់ត្រូវបានគេយល់ថាគឺជាការបញ្ចេញឲ្យដឹងនូវព័ត៌មានដែលពីមុនមក គឺជាការសម្ងាត់ទៅឲ្យភាគីទី៣ ណាម្នាក់ ឬទៅឲ្យសាធារណៈជន ។ ដីកាណាមួយរបស់អង្គជំនុំជម្រះរបស់តុលាការត្រូវតែជាការ "ល្មើសជាសត្យានុម័ត"[89] ។ *បំណងឧក្រិដ្ឋ* ដែលតម្រូវសម្រាប់បទល្មើសនេះ គឺការដឹងរបស់ជនជាប់ចោទថា ការផ្សាយចេញនូវព័ត៌មានជាពិសេសណាមួយគឺជាការដែលធ្វើឡើងដោយរំលោភទៅលើដីការបស់តុលាការ ។ ទាំងមានចេតនាទាំងងងឹតងងល់ក្តី ឬទាំងការធ្វើជាមិនអើពើដោយការធ្វេសប្រហែសក្តី អំពីអត្ថិភាពនៃដីការបស់តុលាការដែលអនុញ្ញាត

---

[84] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Furundzija,* បណ្តឹងជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងជូនទៅរដ្ឋអាជ្ញាស្តីពីសីលធម៌ក្នុងការធ្វើការចោទប្រកាន់ ចុះថ្ងៃទី៥ មិថុនា ១៩៩៨ របស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, កថាខណ្ឌទី១១ ។

[85] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Brdjanin,* សេចក្តីសម្រេចលើញត្តិស្នើសុំលើកលែងការចោទប្រកាន់អនុលោមតាមវិធាន៩៨ស្ទួន ចុះថ្ងៃទី១៩មីនា២០០៤ របស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាកា ICTY , កថាខណ្ឌទី៩-១០ ។

[86] សាលក្រមនៃករណីរឿងរបស់ Marijacic, កថាខណ្ឌទី ៥៤ ។

[87] សាលក្រមនៃករណីរឿងរបស់ Marijacic, កថាខណ្ឌទី ៥៥ ។

[88] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Haxhiu,* សាលក្រមលើការចោទប្រកាន់អំពីការប្រមាថ, សំណុំរឿងលេខ: IT-04-84-R77.5, ចុះថ្ងៃទី២៤ កក្កដា ឆ្នាំ២០០៨, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, កថាខណ្ឌទី១០ ។ [*ចាប់ពីនេះតទៅហៅថា* សាលក្រម Haxhiu ] ។

[89] សាលក្រម Haxhiu, កថាខ័ណ្ឌទី១០ ។

ផ្តល់នូវវិធានការការពារគឺមិនមានពិរុទ្ធភាពគ្រប់គ្រាន់ ក្នុងការប្រព្រឹត្តដែលជាប់ទាក់ទិននិង បទប្រមាថមើលងាយនោះទេ[90] ។

## *អំពីនីតិវិធីដែលត្រូវអនុវត្តតាមនៅក្នុងដំណើរការនៃនីតិវិធី ពីបទប្រមាថមើលងាយ*

៤២. អាស្រ័យដោយលក្ខណៈត្រូវដាក់ទណ្ឌកម្មនៃបទប្រមាថមើលងាយតុលាការ និងដំណើរការនៃនីតិវិធីនៃ "ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ" តុលាការអន្តរជាតិនានាដែលធ្វើការជំនុំជម្រះក្តីលើករណីរឿងក្តីទាំងនេះ បានគិតដល់ការបង្កើតជានីតិវិធីយ៉ាងល្អិតមួយសម្រាប់អនុវត្តតាម នៅមុនពេលចេញសាលក្រមមួយស្តីពីភាពត្រូវមានទោស ឬគ្មានទោសរបស់ជនល្មើសដែលត្រូវបានចោទប្រកាន់ ។ ឧទាហរណ៍ ដូចជាតុលាការ ICC បានថែងអំពីការស៊ើបអង្កេត ការចោទប្រកាន់ និងការជំនុំជម្រះក្តីលើការចោទប្រកាន់បែបនេះនៅមុនពេលដែលសាលក្រមចូលជាធរមាន ។ តុលាការផ្សេងៗទៀតមានទម្លាប់ក្នុងការតែងតាំងជាអង្គជំនុំជម្រះពិសេសផ្សេងៗ ឬជាព្រះរាជអាជ្ញាដែលជាមិត្តពិសេសរបស់តុលាការ (Special *amici* Prosecutors) ដើម្បីធ្វើការចោទប្រកាន់លើករណីរឿងបែបនេះ[91] ។ អង្គជំនុំជម្រះឬ សហព្រះរាជអាជ្ញាទាំងនេះ ជាធម្មតាគឺតែងតែខុសគ្នា ពីអង្គជំនុំជម្រះ ឬពីព្រះរាជអាជ្ញាដែលការចោទប្រកាន់ពីបទប្រមាថមើលងាយ ឬ ជ្រៀតជ្រែកត្រូវបានប្រព្រឹត្តស្ថិតនៅចំពោះមុខខ្លួន[92] ។ តុលាការ ICTY បានធ្វើការកត់សំគាល់ថា សម្រាប់ស្ថាប័នតុលាការមួយដែលត្រូវធ្វើជាព្រះរាជអាជ្ញាផង និងជាចៅក្រមផងដែលទាក់ទងទៅនឹងបទចោទប្រកាន់ អំពីការប្រមាថមើលងាយគឺមានគ្រោះថ្នាក់អំពីការដែលតុលាការនេះ បំភ្លេចចោលនូវ "នីតិវិធី និងកិច្ចការពារធម្មតាសម្រាប់ភាគីនានា"[93] ។ តុលាការនេះបានធ្វើការកត់សំគាល់ថា ដីកាចោទ

---

[90] សាលក្រម Haxhiu, កថាខ័ណ្ឌទី១១ ។

[91] *នៅក្នុងករណីប្រឆាំងនឹង Florence Hartman*, សារណាមុនពេលជំនុំជម្រះរបស់រដ្ឋអាជ្ញា, សំណុំរឿងលេខ: IT-02-54-RR77.5, អង្គជំនុំជម្រះពិសេសនៃតុលាការ ICTY, ចុះថ្ងៃទី៨ មករា ២០០៩, ទំព័រទី១ [*ចាប់ពីនេះតទៅហៅថា* សារណាក្នុងករណី Florence Hartman] ។

[92] សារណាក្នុងករណី Florence Hartman, ទំព័រទី១ ។

[93] សាលក្រម Aleksovski, កថាខ័ណ្ឌទី៥៥ ។

ប្រកាន់ដែលក្នុងនោះជនល្មើសដែលត្រូវបានចោទប្រកាន់ គួរតែ "កំណត់អត្តសញ្ញាណនៃបទចោទឱ្យបានច្បាស់លាស់ដែលជនល្មើសនោះត្រូវឆ្លើយបំភ្លឺ" ហើយគួរតែផ្តល់ឱកាសឱ្យគាត់ក្នុងការជជែកពិភាក្សាអំពីអ្វីដែលតម្រូវឱ្យបង្ហាញភស្តុតាង ដើម្បីជាការបើកឱ្យគាត់ទទួលបាននូវការជំនុំជម្រះក្តីមួយប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌"[94] ។

៤៣. សេចក្តីព្រមានមួយដែលគ្រប់គ្រាន់ និងដោយផ្ទាល់មាត់ គួរត្រូវបានធ្វើឡើងចំពោះជនដែលត្រូវបានគេចោទថាជាអ្នកប្រមាថមើលងាយ ឬជាអ្នកជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការនៅមុនពេលដំណើរការនៃនីតិវិធី ត្រូវបានផ្តួចផ្តើមគំនិតធ្វើប្រឆាំងនឹងរូបគាត់[95] ។ បន្ទាប់ពីនោះ ដំណើរការនីតិវិធីត្រូវបានផ្តួចផ្តើមគំនិតធ្វើក្នុងទម្រង់ជាដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះឬជាដីកាសម្រេចមួយជំនួសឱ្យដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ[96]។

***យោបល់សង្កេតរបស់សហព្រះរាជអាជ្ញាលើដីកាសម្រេចអំពីភាពសម្ងាត់ជាការឆ្លើយតបទៅនឹងការដាក់ទណ្ឌកម្មចំពោះអំពើរំលោភបំពាន***

៤៤. នៅក្នុងដីកាសម្រេចអំពីភាពសម្ងាត់បានរកឃើញថា មេធាវីការពារក្តី (១) មិនបានគោរពតាមលិខិតទាក់ទងរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៥ខែមករាឆ្នាំ២០០៩ ។ (២) បានល្មើស នឹងវិធាន៥៦.១ នៃវិធានផ្ទៃក្នុងដោយបញ្ចេញឱ្យគេដឹងព័ត៌មានសម្ងាត់ ។ (៣) ល្មើសនឹងមាត្រា២១.៣ នៃកិច្ចព្រមព្រៀង ដោយខកខានមិនបានធ្វើសកម្មភាពស្របទៅតាមបទដ្ឋាន និង ក្រមសីលធម៌វិជ្ជាជីវៈមេធាវី ។ ក្នុងដីកាសម្រេចអំពីភាពសម្ងាត់បានកត់សំគាល់ "អំពើល្មើសនេះអាចត្រូវដាក់ទណ្ឌកម្មតាមវិធាន៣៥ និងវិធាន៣៨ នៃវិធានផ្ទៃក្នុង"[97] ។

---

[94] សាលក្រម Aleksovski, កថាខ័ណ្ឌទី៥៥ ។

[95] *រដ្ឋអាជ្ញា ទល់នឹង Musema*, ការព្រមាន និងការជូនដំណឹងដល់មេធាវីការពារក្តី អនុលោមតាមវិធាន៤៦ក នៃវិធានស្តីពីនីតិវិធី និងភស្តុតាង, សំណុំរឿងលេខ: ICTR-96-13-I, ចុះថ្ងៃទី៣១ តុលា ឆ្នាំ១៩៩៧ ។

[96] *នៅក្នុងករណីប្រឆាំងនឹង Florence Hartman*, ដីកាបង្គាប់ជំនួសដីកាបញ្ជូនរឿងទៅជំនុំជម្រះអំពីករណីប្រមាថ, សំណុំរឿងលេខ: IT-02-54-RR77.5, អង្គជំនុំជម្រះពិសេសនៃតុលាការ ICTY, ចុះថ្ងៃទី២៧ សីហា ២០០៨ ។

[97] ដីកាសម្រេចអំពីភាពសម្ងាត់, ទំព័រទី៧ ។

៤៥. ក្រោយពីការរកឃើញនូវអំពើល្មើសទាំងនេះ ដីកាសម្រេចអំពីភាពសម្ងាត់បានណែនាំឱ្យមេធាវីការពារក្តី (១) ឈប់បិទផ្សាយ "ព័ត៌មាន និងឯកសារនានាដែលពាក់ព័ន្ធ នឹងកិច្ចស៊ើបសួរក្រៅពីឯកសារទាំងឡាយដែលបានចុះផ្សាយតាមគេហទំព័រ (Website) របស់ អ.វ.ត.ក" ។ និង (២) ឱ្យដក "ខ្លឹមសារដែលមានការមើលងាយ"ចេញពីគេហទំព័រ (Website) របស់មេធាវីការពារក្តី ឬត្រូវប្រឈមមុខនឹងផលវិបាកតាមផ្លូវច្បាប់ចំពោះការល្មើសដែលលើសពីនេះទៀត ។[98] សហចៅក្រមស៊ើបអង្កេតក៏បានបញ្ជូនផងដែរ នូវដីកាសម្រេចអំពីភាពសម្ងាត់ទៅឱ្យស្ថាប័នអាជីពសម្រាប់ធ្វើការត្រួតពិនិត្យនីមួយៗរបស់មេធាវីការពារក្តី "ដើម្បីឱ្យស្ថាប័នទាំងនេះអាចធ្វើការសម្រេចស្តីពីវិធានការណ៍ដ៏សមស្រប"[99] ។

៤៦. ទោះបីជាសេចក្តីថ្លែងនៅក្នុងដីកាសម្រេចអំពីភាពសម្ងាត់[100] មិនមានភាពច្បាស់លាស់ទាំងស្រុងនោះក្តី ក៏សហព្រះរាជអាជ្ញាជឿថា ដីកាសម្រេចនោះត្រូវបានអនុម័តយល់ព្រមអនុលោមតាម ការរកឃើញនានាអំពីអំពើល្មើសដោយមេធាវីការពារក្តីនោះតាមវិធាន៣៥ និងវិធាន៣៨ នៃវិធានផ្ទៃក្នុង[101] ។ សហព្រះរាអាជ្ញានិងចាត់ទុកថាជាការរកឃើញ អំពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ និងជាកំហុសវិជ្ជាជីវៈ - ប្រសិនបើនេះ គឺជាអ្វីដែលដីកាសម្រេចអំពីភាពសម្ងាត់បានរកឃើញថា-មានលក្ខណៈយ៉ាងធ្ងន់ធ្ងរ ។ ភាពធ្ងន់ធ្ងរនេះ ត្រូវបានត្រូវបានរួមបញ្ចូលគ្នានៅពេលដែលជនទាំងឡាយ ដែលត្រូវបានគេរកឃើញថា បានប្រព្រឹត្តល្មើសគឺជាមេធាវីការពារក្តី ដែលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការនេះ ។ មេធាវីទាំងឡាយទទួលខុសត្រូវនិងត្រូវមានភារកិច្ចចំពោះកូនក្តីរបស់ខ្លួន មានភារកិច្ចដែលលាតសន្ធឹងដ៏ធំចំពោះតុលាការក្នុងនាមជាមន្ត្រីមួយរូបរបស់តុលាការនោះ ភារកិច្ចនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងក្រមសីលធម៌សម្រាប់មេធាវីដែលកាត់ទទឹងខ្សែបន្ទាត់ព្រំដែនរបស់យុត្តាធិការ និងរបស់ជាតិ ។

---

[98] ដីកាសម្រេចអំពីភាពសម្ងាត់, ទំព័រទី៧ ។

[99] ដីកាសម្រេចអំពីភាពសម្ងាត់, ទំព័រទី៧ ។

[100] ដីកាសម្រេចអំពីភាពសម្ងាត់, ទំព័រទី៧ ។ សហព្រះរាជអាជ្ញាចាត់ទុកថា បញ្ញត្តិនេះ រួមបង្កើតបាននូវកថាខ័ណ្ឌនានា បន្ទាប់ពី "សម្រាប់មូលហេតុទាំងនេះ" ។

[101] ដីកាសម្រេចអំពីភាពសម្ងាត់, កថាខ័ណ្ឌទី២០ ។

៤៧. សហព្រះរាជអាជ្ញា សូមធ្វើការកត់សំគាល់ថា មេធាវីការពារក្តីមិនបានចាត់វិធានការដោយការយកចិត្តទុកដាក់មត់ចត់ដើម្បីដោះស្រាយលើបញ្ហាទាំងឡាយ ដែលបានលើកឡើងនៅក្នុងលិខិតទំនាក់ទំនងរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩នោះទេ ដែលជាការបណ្តាលឲ្យមានការចេញដីកាសម្រេចអំពីភាពសម្ងាត់ដែលមានការតវ៉ាដូចនេះ ។

៤៨. ដោយសារតែភាពធ្ងន់ធ្ងរនៃបញ្ហាដែលពាក់ព័ន្ធ និងដោយសារតែការរកឃើញទាំងឡាយប្រឆាំងនឹងមេធាវីការពារក្តី និងសេចក្តីរាយការណ៍ជាបន្តបន្ទាប់មកទៀតជូនដល់ស្ថាប័នអាជីពសម្រាប់ធ្វើការត្រួតពិនិត្យនានារបស់ខ្លួន សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គបុរេជំនុំជម្រះ ធ្វើការពិនិត្យពិចារណាអំពីភាពត្រឹមត្រូវនៃដីកាសម្រេច អំពីភាពសម្ងាត់ដោយពិនិត្យទៅលើការគោរពប្រតិបត្តិតាមក្នុងការថែរក្សាការពារទាំងនីតិវិធី និងខ្លឹមសារ ដូចដែលមានចែងនៅក្នុងវិធាន៣៥ និងវិធាន៣៨ នៃវិធានផ្ទៃក្នុង ។ អង្គបុរេជំនុំជម្រះអាចពិនិត្យពិចារណាទៅ លើកត្តាផ្សេងៗដូចខាងក្រោមនេះ៖

ក. តើដីកាសម្រេចអំពីភាពសម្ងាត់ ត្រូវបានអនុម័តយល់ព្រម ឬអត់បន្ទាប់ពីការស្តាប់ចម្លើយរបស់ភាគីនានានៅក្នុងដំណើរការនីតិវិធីនៅក្នុងសំណុំរឿងលេខ ០០២ ដែលនៅក្នុងនោះការប្រព្រឹត្តអំពើប្រមាថមើលងាយបានកើតឡើង ដើម្បីឲ្យដំណើរការនៃបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ បានទៅដោយអត្ថន័យ នោះដីកាសម្រេចដែលមានការប្រឆាំងតវ៉ា គួរតែត្រូវបានអនុម័តយល់ព្រមបន្ទាប់ពី (១) អាជ្ញាធរមានសមត្ថកិច្ចថ្នាក់ក្រោមរបស់តុលាការបានធ្វើការជូនដំណឹង អំពីចេតនារបស់ខ្លួនចង់សម្រេចទៅលើបញ្ហាណាមួយ ។ (២) ស្តាប់ចម្លើយរបស់ភាគីនានាបន្ទាប់ពីបានផ្តល់នូវឱកាសយ៉ាងសមស្របដល់ពួកគេដើម្បីធ្វើសារណា ។ (៣) ពិនិត្យ ពិចារណា និងដោះស្រាយលើសារណានានារបស់ភាគី និងបន្ទាប់មកផ្តល់មូលហេតុអំពីការយល់ព្រម ឬបដិសេធនូវសារណាទាំងនោះ ។ សហព្រះរាជអាជ្ញាសូម ធ្វើការ កត់សំគាល់ថា ភាគីទាំងឡាយនៃសំណុំរឿងលេខ០០២ មិនបានធ្វើសារណាជូនសហ ចៅក្រមស៊ើបអង្កេត នៅមុនពេលចេញដីកាសម្រេចអំពីភាពសម្ងាត់ទេ ។ ហេតុដូច នេះ ភាគី

ទាំងឡាយត្រូវបង្ហាញជូនអំពីទស្សនៈយល់ឃើញរបស់ខ្លួនជាលើកដំបូង នៅចំពោះមុខវេទិកានៃបណ្តឹងឧទ្ធរណ៍នេះ ។

ខ. ទោះបីជា ដីកាសម្រេចអំពីភាពសម្ងាត់-ជាដីកាសម្រេចជាបទព្រហ្មទណ្ឌមួយដែលដាក់ទណ្ឌកម្មមេធាវីការពារក្តី និងរាយការណ៍អំពីពួកគេទៅឱ្យស្ថាប័នអាជីពសម្រាប់ត្រួតពិនិត្យនានារបស់ពួកគេ-មានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ ដើម្បីចង្អុលបង្ហាញពីការប្រព្រឹត្តអំពើប្រមាថមើលងាយ ពី*ចេតនាឧក្រិដ្ឋ* និង *អំពើពិរុទ្ធ* នៃការប្រព្រឹត្តនោះនិងបញ្ញត្តិច្បាប់ច្បាស់លាស់ទាំងឡាយដែលការដាក់ទណ្ឌកម្មត្រូវបានកំណត់ផ្អែកតាមនោះ ។ តុលាការនានាដែលស្រដៀងគ្នានោះក៏បានចាត់ទុកថាការប្រព្រឹត្តនេះឈានទៅដល់ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ និង ជាកំហុសវិជ្ជាជីវៈរបស់មេធាវី បញ្ហាដែលរៀបរាប់លំអិតនៅក្នុងឯកសារចោទដើម្បីជូនដំណឹងដល់ជនល្មើស អំពីប្រភេទនៃបទចោទប្រកាន់នានាដែលខ្លួននឹងត្រូវគេចោទ ។ សាលក្រម/ដីកាសម្រេចនានានៅលើឯកសារចោទប្រកាន់ទាំងនេះ បន្ទាប់មកត្រូវបានចេញនៅ ក្រោយពេលស្តាប់ចម្លើយរបស់ជនដែលត្រូវចោទថាជាអ្នកប្រព្រឹត្តល្មើស និងពិចារណាទៅលើសក្ខីកម្មរបស់សាក្សី និងភស្តុតាងជាឯកសារ ប្រសិនបើមានការតម្រូវ។ សាលក្រម/ដីកាសម្រេចទាំងនេះរៀបរាប់យ៉ាងលំអិតអំពីសារណាទាំងឡាយរបស់ភាគី និងអំពីបញ្ញត្តិច្បាប់ជាក់លាក់ដែលជនដែលត្រូវគេចោទថាជាជនល្មើសត្រូវបានរកឃើញថាមានទោស ឬក៏យ៉ាងណាមួយ ដោយផ្អែកតាមបញ្ញត្តិច្បាប់ទាំងនេះ ។ នេះគឺដើម្បីធានាឱ្យប្រាកដថា ដំណើរបណ្តឹងឧទ្ធរណ៍នេះពោរពេញដោយអត្ថន័យ ជាពិសេស ប្រសិនបើមានឧបាស្រ័យសម្រាប់ដើមបណ្តឹងឧទ្ធរណ៍តែម្នាក់គត់ប៉ុណ្ណោះ ។ សហព្រះរាជអាជ្ញា សូមធ្វើការកត់សំគាល់ថា មិនមានឯកសារចោទប្រកាន់ណានៅក្នុងសំណុំរឿងដែល៖ (១)ផ្តល់អត្តសញ្ញាណយ៉ាងលំអិតអំពីអំពើល្មើសនានានោះទេ ។ (២) បានចែងថា អំពើទាំងនោះត្រូវបានធ្វើឡើង "ដោយបានដឹង និងដោយចេតនា" នោះទេ ។ និងតើធ្វើដូចម្តេច (៣) ធ្វើដូចម្តេចឲ្យការប្រព្រឹត្តនេះឈានទៅដល់ការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការទៅ ។ (៤) តើ "ព័ត៌មាន"សំងាត់អ្វីខ្លះដែលត្រូវបានផ្សាយចេញ និងដែលជាការរំលោភទៅលើ "ដីកា" របស់តុលាការ

នោះ[102] ។ ឯកសារនេះមានការចាំបាច់ជាពិសេស ប្រសិនបើការដាក់ទណ្ឌកម្មផ្សេងៗ កំពុងតែត្រូវបានចាត់ទុកថាត្រូវបានធ្វើឡើង "ក្រៅប្រព័ន្ធតុលាការ"[103] ។

គ. តើទាំងឡាយដែលកំពុងតែត្រូវបានពិចារណា ដើម្បីដាក់ទណ្ឌកម្មជាការផ្តន្ទាទោស បានទទួលការណែនាំ អំពីការមានសិទ្ធិក្នុងការទទួលបាននូវជំនួយផ្នែកច្បាប់ នៅមុនពេលចេញដីកាសម្រេចអំពីភាពសម្ងាត់ដែរឬទេ? ។ នេះគឺជាលក្ខខណ្ឌតម្រូវដែលចាំបាច់ខានមិនបានតាមវិធាន៣៥.៣ ដូចដែលបានចង្អុលបង្ហាញដោយការប្រើពាក្យ "ត្រូវ"[104] ។ គ្មានអ្វីនៅក្នុងសំណុំរឿងដែលមានស្រាប់ទេ សម្រាប់ធ្វើសេចក្តីសន្និដ្ឋានអំពីថាតើឱកាសនេះត្រូវបានគេផ្តល់ទៅឲ្យមេធាវីការពារក្តីដែរឬទេ?

ឃ. តើក្នុងដីកាសម្រេចអំពីភាពសម្ងាត់ ឬការព្រមានណាមួយ ឬក៏ឯកសារចោទប្រកាន់ណាមួយ ដែលជាបុព្វបទរបស់ឯកសារនោះ បានកំណត់អត្តសញ្ញាណអំពីតើបញ្ញត្តិច្បាប់ណាខ្លះរបស់កម្ពុជា ដែលមានការបង្ខំត្រូវតែអនុវត្តតាមដោយខានមិនបាន ដែរឬទេ "ទាក់ទងនឹងការដាក់ទណ្ឌកម្មដែលធ្វើទៅលើជនណាម្នាក់ [តាមវិធាន៣៥.១]" ។ គ្មានឯកសារណាដើម្បីនឹងធ្វើសេចក្តីសន្និដ្ឋានថាភាពច្បាស់លាស់នេះ មានចែងនៅក្នុងឯកសារណាមួយនោះទេ ។

ង. តើមានការព្រមានណាមួយ-ដែលបានកំណត់ដោយវិធាន៣៨.១ -ត្រូវបានគេផ្តល់ទៅឲ្យមេធាវីការពារក្តី នៅមុនពេលពួកគេត្រូវបានរកឃើញថាបានប្រព្រឹត្តកំហុសវិជ្ជាជីវៈដូចដែលមានចែងនៅក្នុងវិធាននោះទេ ។ យុត្តិសាស្ត្រអន្តរជាតិដែលក្នុងនោះ មានបទដ្ឋានផ្សេងៗដែលតុលាការនេះត្រូវចាប់កាតព្វកិច្ចអនុវត្តតាមនោះ បានតម្រូវឲ្យជនណាដែលត្រូវបានចាត់ទុកថាបានរំលោភបំពាន គួរតែត្រូវបានធ្វើការព្រមានឲ្យបានទាន់ពេលវេលានៅមុនពេលត្រូវធ្វើការដាក់ទណ្ឌកម្មលើរូបគាត់ ឬមួយក៏ត្រូវធ្វើការ

---

[102] វិធាន៣៥.១ និង៣៥.១.ក នៃវិធានផ្ទៃក្នុង។

[103] វិធាន៣៥.២.ក នៃវិធានផ្ទៃក្នុង។

[104] វិធាន៣៥.៣ នៃវិធានផ្ទៃក្នុង។

រឹតបន្តឹងលើសិទ្ធិរបស់គាត់[105] ។ ការព្រមានគួរតែ "ចង្អុលបង្ហាញឲ្យបាន*ជាក់លាក់*ថា ការប្រព្រឹត្តដែលជា[បទល្មើស] ប្រសិនបើចេះតែបន្តកើតមានតទៅទៀតនោះអាចនឹងបណ្តាលឲ្យមានការរឹតបន្តឹងជាក់លាក់ណាមួយជាពុំខាន" ។ ក្នុងការធ្វើតាមរបៀបនេះ អាចនឹងលែងមានបញ្ហាអំពីថា [ជនដែលគេចោទថាជាជនល្មើស]ត្រូវបានគេផ្តល់ការជូនដំណឹងថា ការព្រមានមានលក្ខណៈធ្ងន់ធ្ងរហើយដែលអាចនឹងបណ្តាលឲ្យមានការ [ដាក់ទណ្ឌកម្មផ្សេងៗ] ប្រសិនជាមិនព្រមស្តាប់តាមការព្រមាននេះទេនោះ[106]។ អង្គបុរេជំនុំជម្រះអាចពិនិត្យពិចារណាអំពីថាតើលិខិតទំនាក់ទំនងរបស់សហ ចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៥ ខែមករាឆ្នាំ២០០៩ បំពេញបានគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវនៃការព្រមានដ៏ជាក់លាក់នេះដែរឬទេ ។

ច. តើជាការសមស្របសម្រាប់អង្គភាពមួយរបស់តុលាការមួយ- តួយ៉ាងដូចជាសហចៅក្រមស៊ើបអង្កេតនេះដែរឬទេ - ក្នុងការដាក់ទណ្ឌកម្មចំពោះមេធាវីការពារក្តី ដែលត្រូវបានចោទ អំពីបទរំលោភលើដីកាអង្គភាពមួយទៀតរបស់តុលាការ - ដូចជា អង្គបុរេជំនុំជម្រះនេះ - នៅពេលដែលដែលតុលាការនេះ ត្រូវជាប់កាតព្វកិច្ចភាពមួយទៀតនោះគឺជាវេទិកាដែលមានលក្ខណៈសមស្របជាង ដើម្បីធ្វើការសម្រេចអំពីបទរំលោភបំពានដូចជា ឯកសារដែលមាន "ការប្រមាថមើលងាយ" ទាំងឡាយដែលត្រូវបានដាក់ចំពោះមុខអង្គបុរេជំនុំជម្រះនេះនិងដែលអាចឲ្យអង្គបុរេនេះធ្វើការសន្និដ្ឋានបានល្អប្រសើរជាងខាងអង្គច្បាប់ក៏ដូចជាខាងសមធម៌អំពីថាតើការរំលោភបំបាននេះចាំបាច់ត្រូវធ្វើការដាក់ទណ្ឌកម្មដែរឬទេ? ហើយបើសិនជាត្រូវដាក់នោះ តើត្រូវដាក់ត្រឹមកំរិតណា? ។

---

[105] *វណ្ណអាជ្ញា ទល់នឹង Seseji*, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការចាត់តាំងមេធាវីការពារក្តី, សំណុំរឿងលេខ: IT-03-67-AR73.3, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី២០ តុលា ២០០៦, កថាខ័ណ្ឌទី២៣ ។ [*ចាប់ពីនេះតទៅហៅថា* សាលដីកាសម្រេចលើ Seseji] ។

[106] សេចក្តីសម្រេចលើករណី Seseji, កថាខ័ណ្ឌទី២៥ ។

ឆ. តើការរកឃើញក្រៅប្រព័ន្ធតុលាការ អំពីមានការជ្រៀតជ្រែកចូលក្នុងការងាររដ្ឋបាលរបស់តុលាការ និងអំពីកំហុសវិជ្ជាជីវៈដែលប្រឆាំងទៅនឹងមេធាវីការពារក្តី និងអំពីផលវិបាកនៃការទំនាក់ទំនងគ្នាទៅកាន់ស្ថាប័នអាជីព សម្រាប់ធ្វើការត្រួតពិនិត្យទាំងឡាយរបស់ពួកគេមានលក្ខណៈសមាមាត្រទៅនឹង "បទល្មើស"ដែរឬទេ?[107] ។ សហព្រះរាជអាជ្ញាសូមធ្វើការកត់សំគាល់ថា ដីកាសម្រេចអំពីភាពសម្ងាត់ មិនបានចោទប្រកាន់អំពី "*ព័ត៌មាន*"[108] សម្ងាត់ ឬដែលត្រូវការពារណាមួយ "ដែលទាក់ទងទៅនឹងជនរងគ្រោះ ឬសាក្សី ឬការស៊ើបសួរដែលត្រូវបានផ្សាយចេញនោះទេ។ ចំពោះការរំលោភលើដីការបស់តុលាការវិញ - បើសិនជាមានការបង្ហាញភស្តុតាងថា ក្រោយពីជនល្មើសត្រូវបានគេផ្តល់ឱកាសឲ្យ ក្នុងការស្តាប់ចម្លើយហើយថា - គឺជាបញ្ហា ដែលមានលក្ខណៈធ្ងន់ធ្ងរនោះ អង្គភាពមួយរបស់តុលាការមិនគួរត្រូវបានគេមើលឃើញថាធ្វើការផ្តន្ទាទោសពីបទព្រហ្មទណ្ឌចំពោះមេធាវីការពារក្តី ដោយសារតែពួកគេការពារសិទ្ធ ដែលត្រូវទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌នៃកូនក្តីរបស់ពួកគេនោះទេ ។

ជ. តើគួរតែមានការចង្អុលបង្ហាញមួយ អំពីការជ្រៀតជ្រែកជាក់ស្តែងចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ នៅមុនពេលជនណាម្នាក់ត្រូវបានគេដាក់ទណ្ឌកម្មតាមវិធាន៣៥ដែរឬទេ? ។

៤៩. សហព្រះរាជអាជ្ញា សូមធ្វើការបញ្ជាក់ជាថ្មីឡើងវិញថាការបង្ហាញភស្តុតាងណាមួយឲ្យឃើញអំពីមានការរំលោភលើដីកាណាមួយរបស់តុលាការ - ជាពិសេសគឺដោយមេធាវីការពារក្តី - គឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ ដោយសារវាប៉ះពាល់ទៅដល់កិច្ចការរដ្ឋបាលរបស់តុលាការ ។ ការរំលោភបំពានណាមួយ បើសិនជាមានភស្តុតាងបង្ហាញថា បានប្រព្រឹត្តដោយមានការដឹង និងដោយចេតនានោះ គឺត្រូវតែធ្វើការត្រួតពិនិត្យ ដោយត្រូវមានផលវិបាកជាទោសព្រហ្មទណ្ឌដ៏សម

[107] *Handyside ទល់នឹង ចក្រភពអង់គ្លេស*, សាលក្រម, ចុះថ្ងៃទី៧ ធ្នូ ឆ្នាំ១៩៧៦, Series A, No. 24 (1979-1980) 1 EHHR 737, កថាខ័ណ្ឌទី៤៨-៥០ ។

[108] វិធាន៣៥.១.ក នៃវិធានផ្ទៃក្នុង។ សង្កត់ធ្ងន់ត្រង់*អក្សរទ្រេត* ។

ស្រប ។ ក៏ប៉ុន្តែដោយសារតែភាពដ៏ធ្ងន់ធ្ងរនេះ ប្រសិនបើមាន ការរំលោភបំពានមែននោះ ត្រូវតែធ្វើការសម្រេចក្រោយពីបានផ្តល់ដល់ជនដែលត្រូវចោទថា ជាអ្នកប្រព្រឹត្តល្មើសនូវឱកាសដ៏សមស្របមួយដើម្បីឆ្លើយបំភ្លឺ បន្ទាប់ពីត្រូវបានធ្វើការព្រមានមួយអំពីថានឹងត្រូវទទួល នូវផលវិបាកជាការផ្តន្ទាទោសជាបទព្រហ្មទណ្ឌ បើសិនជាអំពើបំពាននោះនៅតែបន្តធ្វើតទៅទៀត ។ បើសិនជាជនល្មើសនៅតែបន្តអំពើបំពានដែលទោះបីជាមានការព្រមានដ៏ជាក់លាក់ហើយក៏ដោយនោះ ដំណើរការនីតិវិធីអាចនឹងត្រូវបានផ្តួចផ្តើមគំនិតធ្វើឡើងដើម្បីប្រឆាំងនឹងរូបគាត់ដោយមានឯកសារចោទប្រកាន់ជាក់លាក់មួយ ដើម្បីបើកឱកាសឲ្យគាត់ដើម្បីរកមេធាវីការពារក្តីមួយរូប ប្រសិនបើមាន ។ ជនដែលត្រូវចោទថាជាអ្នកប្រព្រឹត្តល្មើស ទោះបីខ្លួនជាមេធាវីស្រាប់ហើយក៏ដោយ ក៏គួរតែត្រូវបានអនុញ្ញាតឲ្យស្វែងរកជំនួយការផ្នែកច្បាប់ដែរ តាមការតម្រូវខាងមិនបានដូចមានចែងនៅក្នុងវិធាន៣៥.៣ ។ គឺតែនៅក្រោយពេលដែលការថែរក្សាការពារផ្នែកនីតិវិធីបែបនេះត្រូវបានអនុម័តយល់ព្រមរួចហើយតែប៉ុណ្ណោះ បើសិនជាមានការរកឃើញមានភាពធ្ងន់ធ្ងរ "អំពីមានការជ្រៀតជ្រែកចូលក្នុងកិច្ចការរបស់តុលាការ" និងអំពីមានកំហុសវិជ្ជាជីវៈរបស់មេធាវីនៅក្នុងនោះ ។

៥០. ឆ្លងតាមការពិនិត្យមើលឡើងវិញទៅលើអង្គហេតុ និងឯកសារដែលមាននៅក្នុសំណុំរឿង សហព្រះរាជអាជ្ញាបានសង្កេតឃើញថា វាមុខជានឹងបំរើឲ្យផលប្រយោជន៍យុត្តិធម៌ ប្រសិនជាអង្គបុរេជំនុំជម្រះ បានពិចារណាអំពីការបញ្ជូនបណ្តឹងឧទ្ធរណ៍ត្រឡប់ទៅឲ្យសហចៅក្រមស៊ើបអង្កេតវិញ ដើម្បីធ្វើការពិនិត្យពិចារណាជាថ្មីឡើងវិញ បន្ទាប់ពីបានគោរពអនុវត្តតាមការថែរក្សាការពារខាងផ្នែកនីតិវិធីដែលត្រូវបានធានាអះអាង អនុលោមតាមវិធាន៣៥ និង៣៨ នៃវិធានផ្ទៃក្នុង ។

## ៦. សេចក្តីសន្និដ្ឋាន

៥១. សេចក្តីដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញា សូមធ្វើសេចក្តីសន្និដ្ឋានដូចខាងក្រោមនេះជូនអង្គបុរេជំនុំជម្រះដើម្បីធ្វើការពិចារណា៖

D138/1/5

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៨)*

i. អង្គបុរេជំនុំជម្រះ អាចពិនិត្យពិចារណាបដិសេធចោលនូវបណ្តឹងឧទ្ធរណ៍នេះ ដោយសារតែមិនមានសិទ្ធប្តឹង និងសំអាងនៃបណ្តឹងរបស់ដើមបណ្តឹងឧទ្ធរណ៍ អៀង សារី និង ដោយសារតែត្រូវបានរាំងដោយវិធាន៧៤.៣ ។ ឬក៏

ii. អង្គបុរេជំនុំជម្រះ អាចពិនិត្យពិចារណាបដិសេធចោលនូវបណ្តឹងឧទ្ធរណ៍នេះ ដោយមិនធ្វើឲ្យខូចប្រយោជន៍ ដោយការអនុញ្ញាតឲ្យមេធាវីការពារក្តីស្វែងរកឧបាស្រ័យតាមរយ:ដំណោះស្រាយផ្សេងៗបែបនេះ ដែលអាចមានស្រាប់សម្រាប់ពួកគេទៅតាមច្បាប់ ។ ឬមួយក៏

iii. ផ្ទុយពីនេះ អង្គបុរេជំនុំជម្រះ អាចយល់ព្រមទទួលបណ្តឹងឧទ្ធរណ៍ដែលមេធាវីការពារក្តីបានដាក់មកនេះក្នុងនាមជាបុគ្គលផ្ទាល់ខ្លួន ។ និង

iv. តាមអង្គហេតុ និងកាល:ទេស:ជាក់ស្តែងនៃបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះ អាចពិនិត្យពិចារណាក្នុងការបញ្ជូនត្រឡប់បណ្តឹងនេះទៅឲ្យសហចៅក្រមស៊ើបអង្កេតវិញ ដើម្បីចាត់ការក្រោយពីបានផ្តល់ដល់មេធាវីការពារក្តីទាំងនោះ នូវឱកាសមួយដ៏សមស្របក្នុងការធ្វើសវនាការមួយ ។ អង្គបុរេជំនុំជម្រះ អាចពិចារណាក្នុងការចេញជាសេចក្តីណែនាំខ្លះៗស្តីពីភាពសម្ងាត់នៃឯកសារ នៅក្នុងអម្លុងពេលដំណើរការនីតិវិធីមុនសវនាការ ដែលមុខជានឹងគ្រប់គ្រងទៅលើ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីការបញ្ជូនត្រឡប់មកវិញ ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩

សហព្រះរាជអាជ្ញា

CO-PROSECUTORS CO-PROCUREURS ECCC CETC

| | |
|---|---|
| លោកយ៉េត ចរិយា | លោក Robert PETIT |
| សហព្រះរាជអាជ្ញារង | សហព្រះរាជអាជ្ញា |